**BMI0028**

# សម្ភាសន៍ជាមួយ មុត រាម ភេទស្រី អាយុឆ្នាំ៥៨

## មុខងារសម័យខ្មែរក្រហមៈ សិល្បៈមជ្ឈិម

## ស្រុកកំណើតនៅភូមិព្រៃកអន្តរថ្មី ឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប

## រស់នៅភូមិវត្តចាស់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃ១៨ ខែតុលា ឆ្នាំ២០១០

## សម្ភាសដោយ សោម ប៊ុនថន

## ០១:៤៥:១៥

## ៤២ទំព័រ

ប៊ុនថន ៖ មីងឈ្មោះអី?

រាម ៖ មុត រាម ។

ប៊ុនថន ៖ មីងស្រុកកំណើតនៅភូមិឃុំអី?

រាម ៖ នៅខេត្តសៀមរាប ឃុំជីក្រែង ភូមិព្រៃកអន្តរថ្មី ។

ប៊ុនថន ៖ ស្រុក?

រាម ៖ ជីក្រែង ។

ប៊ុនថន ៖ មីងមានបងប្អូនប៉ុន្មាននាក់?

រាម ៖ បងប្អូន៨នាក់ ។

ប៊ុនថន ៖ មីងកូនទីប៉ុន្មាន?

រាម ៖ ខ្ញុំកូនទី៧ ។

ប៊ុនថន ៖ មីងមានបានរៀនទេ?

រាម ៖ អត់បានរៀនបន្តិចទេ ។

ប៊ុនថន ៖ មីងចូលសិល្បៈនៅឆ្នាំប៉ុន្មាន?

រាម ៖ ៧០គត់ ។

ប៊ុនថន ៖ កាលនោះគេរើសចូល?

រាម ៖ អត់រើសចូលទេ ។ កាលនោះបងខ្ញុំជីដូនមួយវាចូលធ្វើខ្មែរក្រហម ដល់ពេលនេះទៅ ម៉ែខ្ញុំពូកែវាយខ្ញុំពេក វាមកយកខ្ញុំទៅ ។

ប៊ុនថន ៖ បងជីដូនមួយស្រី ឬប្រុស?

រាម ៖ ស្រី ។

ប៊ុនថន ៖ គាត់អាយុច្រើនជាងមីង?

រាម ៖ ច្រើន ។

ប៊ុនថន ៖ គាត់ខាងអី?

រាម ៖ ខាងសិល្បៈ ។

ប៊ុនថន ៖ គាត់ចូលមុន?

រាម ៖ ចូលមុន ។

ប៊ុនថន ៖ គាត់នៅរស់ទេរាល់ថ្ងៃ?

រាម ៖ នៅរស់ រហូតសព្វថ្ងៃនេះ ។

ប៊ុនថន ៖ រស់នៅណា?

រាម ៖ រស់នៅសៀមរាប នៅស្រុកខ្ញុំ នៅជីក្រែង ។

ប៊ុនថន ៖ គាត់ឈ្មោះអី?

រាម ៖ ឈ្មោះ វឿន

ប៊ុនថន ៖ ត្រកូលគាត់ឈ្មោះអី?

រាម ៖ ត្រកូលគាត់ឈ្មោះអីទេ ខ្ញុំមិនសូវចាំដែរ ។

ប៊ុនថន ៖ គាត់រស់នៅភូមិឃុំអីដែរ?

រាម ៖ ភូមិជាមួយគ្នា ភូមិព្រៃកអន្លុងថ្មី ។

ប៊ុនថន ៖ កាលគាត់ហៅមីងទៅ មីងអាយុប៉ុន្មានឆ្នាំ?

រាម ៖ កាលហៅខ្ញុំទៅអាយុទើបនឹង១០ឆ្នាំ ។

ប៊ុនថន ៖ នៅក្មេងតូច?

រាម ៖ តូច ខ្ញុំចេះតែទៅ ។

ប៊ុនថន ៖ គាត់មកហៅមីង?

រាម ៖ ចា៎ ។

ប៊ុនថន ៖ ម៉ែឪមីងដឹងទេ?

រាម ៖ ម៉ែឪអត់ដឹង លួចទៅ ម៉ែខ្ញុំទៅស្រែ ។ ប៉ុនបងប្រុសខ្ញុំដឹងគាត់មិនឲ្យទៅទេ តែខ្ញុំចចេស ។

ប៊ុនថន ៖ បងប្រុសមីងឃាត់?

រាម ៖ ឃាត់ឲ្យទៅទេ ប៉ុនខ្ញុំចេះតែទៅ ។

ប៊ុនថន ៖ ក្រោយមកម្ដាយមីងដឹងទេ?

រាម ៖ ដឹងគាត់អត់ទៅតាម ។ ទៅតាមក៏ខ្ញុំអត់ហ៊ានមកដែរ ខ្លាចគាត់វាយ ។

ប៊ុនថន ៖ ម៉េចបានគាត់វាយមីង?

រាម ៖ ម៉ែខ្ញុំ ជីវភាពគាត់លំបាកលំបិន គាត់ហត់ពេកអីចឹង គាត់ចេះតែវាយ ។

ប៊ុនថន ៖ ប្រើធ្វើការ?

រាម ៖ ពេលធ្វើការ យើងធ្វើអីអត់ទាន់ចិត្តគាត់ ។

ប៊ុនថន ៖ មីងអត់ចង់នៅទៅជាមួយបងជីដូនមួយ?

រាម ៖ ទៅជាមួយបងជីដូនមួយ ។

ប៊ុនថន ៖ ទៅនៅណា?

រាម ៖ នៅសៀមរាប ប៉ុននៅក្នុងមន្ទីរ នៅក្នុងមន្ទីរស្មារលោត នៅក្នុងព្រៃ ។

ប៊ុនថន ៖ គេហៅ?

រាម ៖ ហៅមន្ទីរស្មារលោត នៅក្នុងព្រៃ ម៉ាជំនាន់យើងខ្មែរក្រហម យើងនៅក្នុងព្រៃ ។ ពេលយើងចេញសម្ដែងមក យើងចេញមកនៅតាមភូមិ សម្ដែងចប់យើងចូលទៅក្នុងមន្ទីរវិញ ។

ប៊ុនថន ៖ គាត់ជាប្រធានខាងជ្រើសរើស(បងជីដូនមួយ) ?

រាម ៖ ប្រធានជ្រើសរើស ។

ប៊ុនថន ៖ ប្រធានខាងសិល្បៈ?

រាម ៖ ប្រធានគេហ្នឹងប្រុស ឈ្មោះ ពូមុញ ។ តែដល់ស្រីហ្នឹងគាត់ដូចថាអនុអីចឹង ជាសមាជិកសាខារបស់គាត់ ។

ប៊ុនថន ៖ មន្ទីរស្មារលោតនៅទីរួមខេត្ត?

រាម ៖ ខេត្តសៀមរាប ប៉ុននៅភូមិពង្រ ម៉ាជួរជីក្រែង ប៉ុនមកលើទៀត គេហៅភូមិពង្រ ។

ប៊ុនថន ៖ ឃុំមីងចាំទេ?

រាម ៖ អត់ចាំឃុំទេ ។

ប៊ុនថន ៖ នៅស្រុកស្ទឹវិញ?

រាម ៖ មិនដឹងនៅស្រុកស្ទឹទេ ។ វាមិនខុសពីស្រុកជីក្រែងទេ ស្រុកនេះស្រុកតែមួយ តែស្រុកវាធំ

ប៊ុនថន ៖ ឆ្ងាយពីផ្ទះទេ?

រាម ៖ ឆ្ងាយពីគ្នា ។

ប៊ុនថន ៖ មីងមកដល់ដំបូងធ្វើអី?

រាម ៖ ខ្ញុំមកគេមានឲ្យធ្វើអីផង ឲ្យតែហាត់សិល្បៈ ព្រោះកន្លែងហ្នឹងមានចូលធ្វើស្រី ។ កន្លែងហ្នឹងសម្រាប់ហាត់សិល្បៈ មានតែប៉ុណ្ណឹងអត់មានឲ្យធ្វើអីទេ ស្រែចំការក៏អត់បានធ្វើដែរ ។ តែមានថ្ងៃណាយើងទំនេរអី គាត់ឲ្យយើងទៅកាប់ចំការតិចតួច ដាំបន្លែបន្ការហូបខ្លួនឯងខ្លះមានប៉ុណ្ណឹង ។

ប៊ុនថន ៖ មានច្រើនទេ?

រាម ៖ ច្រើនដែរ ។ គ្នាច្រើនដែរ គ្នាប្រហែលជាប់១០០នាក់ ។ ហ្នឹងតែអង្គភាពសិល្បៈ តែសងខាង ពួកយោធាគេនៅជុំវិញ ។

ប៊ុនថន ៖ ទំនាក់ទំនងគ្នាជាមួយយោធាធម្មតា?

រាម ៖ និយាយទាក់ទងគ្នាធម្មតា ។ ពេលគេមានការអាសន្នក្រ គេទាក់ទងគ្នា គេប្រាប់យើងកន្លែងសិល្បៈឲ្យប្រយ័ត្នប្រយែង ដូចពេលទាហានខ្មែរឡើងវាយ ។

ប៊ុនថន ៖ ខាងយោធាគ្រប់គ្រងដោយឡែកពីសិល្បៈ?

រាម ៖ គ្រប់គ្រងដោយឡែក ។

ប៊ុនថន ៖ ពីណាអ្នកគ្រប់គ្រង?

រាម ៖ ខាងយោធាខ្ញុំមិនសូវស្គាល់ទេ ប៉ុនមន្ទីរនៅមិនឆ្ងាយគ្នា ។ ចេញចូលបាន ទាក់ទងគ្នាបានមេៗគេ ។

ប៊ុនថន ៖ ខាងសិល្បៈមានប្រុសៗ?

រាម ៖ ប្រុសស្រីធម្មតា ។

ប៊ុនថន ៖ ប៉ុនពេលស្នាក់នៅយ៉ាងម៉េចដែរ?

រាម ៖ ស្នាក់នៅន្លែងខុសគ្នា កន្លែងប្រុសៗផ្សេង កន្លែងស្រីៗផ្សេង រោងខុសគ្នាទាំងអស់ ។ គ្រាន់តែយើងហាត់រាំរែកទៅយើងមកជុំគ្នា តែប៉ុណ្ណឹងឯង ។

ប៊ុនថន ៖ មានគ្រួសារទេអ្នកសិល្បៈ?

រាម ៖ ភាគច្រើនអត់មានទេ ។

ប៊ុនថន ៖ បងជីដូនមួយអ្នកមីងក៏អត់មានដែរ?

រាម ៖ គាត់អត់ទាន់មាន ។

ប៊ុនថន ៖ កាលនោះអាយុគាត់ប៉ុន្មាន?

រាម ៖ កាលនោះអាយុគាត់ខ្ទង់២០ជាងហើយ ។

ប៊ុនថន ៖ មីងហាត់យូរទេ?

រាម ៖ ហាត់យូរដែរ ហាត់ទំរាំតែយើងចេះ ហាត់ជាប់មួយខែទៅពីរខែបានយើងចេញទៅសម្តែងបាន ។

ប៊ុនថន ៖ ហាត់ពីអីខ្លះ?

រាម ៖ ហាត់ពីរបាំយោធា និងរបាំយុវជនយើង ឧទាហរណ៍ថា យើងដាំបន្លែបន្ការ ធ្វើដល ស្ទូងដក ។

ប៊ុនថន ៖ ហាត់ធ្វើកាយវិការ?

រាម ៖ ហាត់ធ្វើកាយវិការ ។

ប៊ុនថន ៖ ចុះច្រៀងមានហាត់ទេ?

រាម ៖ ច្រៀងក៏គេអ្នកច្រៀងផ្សេង អ្នកគេសម្លេងបាន គេច្រៀងទៅ ហើយខ្ញុំសម្លេងមិនសូវបានអ្នកខាងរបាំទៅ ។

ប៊ុនថន ៖ គ្រូបង្ហាតត្រូវជាមីងរបស់មីង?

រាម ៖ មីងខ្ញុំមួយ ហើយនឹងបង ហាន ស្រីនឹងមួយ មានពីនាក់ហ្នឹងអ្នកបង្ហាត់ ។ ផ្នែកកាយវិការ ។

ប៊ុនថន ៖ គាត់ធ្លាប់ហាត់ពីមុនទេ បងជីដូនរបស់មីង?

រាម ៖ គាត់អត់ដែលចេះទេពីដើម គាត់ទើបនឹងចេះពេលខ្មែរក្រហមចូល ។

ប៊ុនថន ៖ គាត់ដែលរៀនសាលាសិល្បៈ?

រាម ៖ អត់ដែលទេ ។

ប៊ុនថន ៖ គាត់ចេះមកពីខាងសិល្បៈ?

រាម ៖ គាត់ច្នៃតាមកន្លែងសាច់របាំ ចម្រៀង ធ្វើកាយវិការតាមខ្លឹមសាររបាំ ចម្រៀង ចេះតែធ្វើទៅ ។

ប៊ុនថន ៖ មីង ហាន នោះគាត់ប្រធានដែរ?

រាម ៖ បង ហាន ជាសមាជិក ។

ប៊ុនថន ៖ ប្រុសៗមានបង្ហាត់ទេ?

រាម ៖ ប្រុសៗមានពីរនាក់ដែរ ។

ប៊ុនថន ៖ ឈ្មោះអីខ្លះ?

រាម ៖ ឈ្មោះ វុធ មួយ ហើយឈ្មោះ ចេក មួយ ។

ប៊ុនថន ៖ គាត់នៅរស់ទេសព្វថ្ងៃនេះ?

រាម ៖ អត់ដឹង បែកគ្នាអស់ចឹង ដឹងរស់ដឹងស្លាប់ ។

ប៊ុនថន ៖ ចុះ ហាន នៅរស់ទេ?

រាម ៖ អត់ដឹងដែរ បែកគ្នាអស់ ។ ខ្ញុំដឹងតែបងជីដូនមួយ កាលខ្ញុំទៅលេងផ្ទះឥឡូវៗគាត់នៅ ដឹងតែប៉ុណ្ណឹង ផុតតែពីនោះមិនដឹងជាយ៉ាងណាយ៉ាងណី ។

ប៊ុនថន ៖ មីងទៅហាត់នោះចូលចិត្តខាងសិល្បៈទេ?

រាម ៖ ធម្មតា ចូលចិត្តដែរ ។

ប៊ុនថន ៖ មានចំណង់ចំណូលចិត្តទេ?

រាម ៖ និស្ស័យយើងខាងណឹង តាមនិស្ស័យរបស់យើងក្មេង ។

ប៊ុនថន ៖ ក្រៅពីហាត់មីងធ្វើអីទៀត?

រាម ៖ ក្រៅពីហាត់ អត់មានធ្វើអីទេ កាប់ចំការបន្តិចបន្តួច ដាំបន្លែបង្ការហូបចុកខ្លួនឯង នៅការពារអង្គភាពខ្លួនឯង អត់មានធ្វើអីទេ ។

ប៊ុនថន ៖ គេហៅអង្គភាពអីវិញ?

រាម ៖ តំបន់៣៥ ។

ប៊ុនថន ៖ សិល្បៈ?

រាម ៖ សិល្បៈតំបន់៣៥ ។

ប៊ុនថន ៖ មីងហាត់អំបិញម៉ិញរយៈពេលប៉ុន្មាន?

រាម ៖ ប្រហែលជាពីរខែ ។

ប៊ុនថន ៖ ហាត់ហើយមីងមានទៅសម្តែងនៅណា?

រាម ៖ ទៅខាងអីសៀមរាប ទៅខាងភ្នំគូលែន ទៅខាងវ៉ារិន ។ ទៅច្រើនកន្លែងណាស់ បើតាមសម្តែងទៅគ្រប់កន្លែង ។ កន្លែងណាគេធ្វើមីទ្ទិង គឺទៅគ្រប់កន្លែង ។ ឡានគេមកដឹកយកទៅ អត់មានឡាន យើងដើរទៅ ។

ប៊ុនថន ៖ ដើរម៉េចបើឆ្ងាយ?

រាម ៖ ឆ្ងាយជូនណាយើងដើរមួយយប់មួយថ្ងៃ ដេកផ្លូវ ។ យើងដើរ ដេកតាម ដល់ចូលដល់ផ្ទះប្រធានភូមិណាមួយគេទទួលខុសត្រូវ យើងសុំគេសម្រាក បាយទឹកនៅនឹង គេធ្វើបាយទឹកឲ្យយើងហូបឆ្អែត ។ ព្រឹកឡើងយើងលាគាត់ចេញដំណើរទៀតទៅ មានគេអ្នកនាំផ្លូវ ។

ប៊ុនថន ៖ មិនមែនដើរតាមផ្លូវជាតិទេ?

រាម ៖ ដើរកាត់តាមផ្លូវលំយើង គ្មានតាមផ្លូវជាតិទេ ។

ប៊ុនថន ៖ ទៅច្រើនទេពេលសម្តែងម្តងៗ?

ភាម : ច្រើនដែរ គ្នា៥០-៦០នាក់ ។

ប៊ុនថន : ទៅទាំងអស់?

ភាម : អត់ទេ មានអ្នកនៅចាំមន្ទីរខ្លះ ។ ទៅតែអ្នករាំ អ្នកចម្រៀង អ្នកលេងរឿង ហើយអ្នកភ្លេង ។ ដូចថាមួយឡានអស់ហើយ ហើយមួយឡានទៀតដឹកសម្ភារៈដូចជាឆាក ។

ប៊ុនថន : ទៅសម្ដែងម្ដងៗយូរទេ?

ភាម : ទៅសម្ដែងជូនណាមួយខែបានចូលមកមន្ទីរវិញ ដើរលេងគ្រប់កន្លែងដែរ វាច្រើនដែរ ។

ប៊ុនថន : មីទ្ទិងមានពីណាខ្លះមកចូលរួម?

ភាម : ជូនណា អ៊ឹ អៀង សារី គាត់ចូលរួម ។ យើងធ្វើមីទ្ទិង គាត់ចូលរួម អ៊ឹ ខៀវ សំផន អ៊ឹ ធុច ហ្នឹង ។ ប៉ុនដឹងគាត់ទៅយ៉ាងណាយ៉ាងណី ខ្ញុំអត់ដឹងដែរ ។

ប៊ុនថន : អ៊ឹ ធុច ហ្នឹង ឈ្មោះគាត់អី?

ភាម : នាមត្រកូលគាត់ខ្ញុំមិនស្គាល់ដែរ ។

ប៊ុនថន : គាត់ធ្វើអីកាលនោះ?

ភាម : គាត់ក្ដាប់ខាងភូមិភាគ៣០៤ យើងខាងកំពង់ចាម ។

ប៊ុនថន : គាត់គ្រប់គ្រងខាងមីងទេ?

ភាម : អ៊ឹ ធុច គ្រប់គ្រងទាំងភូមិភាគ៣០៤ ទាំងសិល្បៈ ។

ប៊ុនថន : ទាំងក្រុមមីង?

ភាម : ចា៎ ។ ប៉ុនខ្ញុំចល័តចុះឡើង មកខាងសៀមរាបផងចឹង ។ ឧទាហរណ៍ ខ្ញុំទៅរៀនភាគ រៀននៅតំបន់ភូមិភាគ៣០៤ចឹងទៅ ខាងនេះគេគ្រប់គ្រងខ្ញុំ ។ ខ្ញុំរៀនខាងនេះមួយឆ្នាំពីរឆ្នាំ បានខ្ញុំត្រឡប់មកវិញ ។ ត្រឡប់មកវិញ បានខ្ញុំមកបង្ហាត់តំបន់៣៥ ខាងសៀមរាបវិញ ។ ដល់ពេលវាយបែក ១៧ មេសា ដល់ហើយគេក៏ជ្រើសរើសនារីសិល្បៈទៅនៅភ្នំពេញ ។ ថាទៅខ្ញុំនៅសិល្បៈរហូត អត់មានបែងចែក ឆ្វេចឆ្វាចទៅណាទៅណី អត់ទេ ។

ប៊ុនថន : មីងសម្ដែងនៅសៀមរាប បានទៅណាខ្លះ ភ្នំគូលែន?

ភាម : ទៅភ្នំគូលែន ទៅវ៉ារិន ទៅសសរស្ដម ទៅដល់កំពង់ធំ ប៉ុនខ្ញុំមិនចាំស្រុកចាំភូមិទេ យូរពេក ។

ប៊ុនថន : ដើរសម្ដែងចល័ត?

ភាម : ចា៎ ។ ចល័យចុះចល័តឡើង បើដើរមកភ្នំគូលែន ដើររបូតតែម្ដងឡើងភ្នំ ឡើងលើភ្នំ ។

ប៊ុនថន : ទៅកន្លែងទឹកជ្រោះរាល់ថ្ងៃ?

រាម ៖ ចា៎ ទឹកជ្រោះ ដើរឡើងទៅលើនោះ ។

ប៊ុនថន ៖ ដើរពី?

រាម ៖ ដើរចេញពីមន្ទីរទៅ យើងដើររបូត អត់មានឡានជិះ ។

ប៊ុនថន ៖ រយៈពេលប៉ុន្មានថ្ងៃបានដល់លើភ្នំគូលែន?

រាម ៖ រយៈពេលមួយយប់មួយថ្ងៃដល់ ។

ប៊ុនថន ៖ ដើរខ្ជនទទេ?

រាម ៖ ស្ពាយសម្ភារៈ ជួយស្ពាយគ្នា យើងអត់មានអីជិក ។ ខ្វះចែកគ្នាស្ពាយឆាក ខោអាវ ប្រដាប់ប្រដារយើងស្លៀកពាក់ ។

ប៊ុនថន ៖ សម្តែងយ៉ាងម៉េចព្រោះទំរាំទៅដល់អស់កម្លាំង ឬសម្រាកសិនបានចាប់សម្តែង?

រាម ៖ ជូនណាទៅដល់យប់អីចឹង ស្អែកឡើងចាប់ផ្តើមសម្តែង ។ ពេលទៅសម្តែងនៅកំពង់សោម ៧យប់ ៧ថ្ងៃអត់មានបានឈប់ទេ ទាំងយប់ ទាំងថ្ងៃ សម្រាកបានតែពេលហូបបាយបន្តិចៗ ហើយចាប់ផ្តើមសម្តែងទៀត ។

ប៊ុនថន ៖ សម្តែងឲ្យពីណាមើល?

រាម ៖ សម្តែងឲ្យពួកទ័ព គេធ្វើមីទិង អាហ្នឹង៧យប់ ៧ថ្ងៃ ។

ប៊ុនថន ៖ នៅសៀមរាបសិល្បៈតំបន់រយៈពេលប៉ុន្មាន បានមីងផ្លាស់ទៅកន្លែងផ្សេង?

រាម ៖ ខ្ញុំនៅមន្ទីរសៀមរាបប្រហែលបាន៥ឆ្នាំ បានខ្ញុំឡើងមកភាគទៀត ។

ប៊ុនថន ៖ ភាគទៅណាវិញ?

រាម ៖ ភាគ៣០៤មកសិល្បៈ ។

ប៊ុនថន ៖ នៅខេត្តណា?

រាម ៖ នៅខាងកំពង់ចាម ។

ប៊ុនថន ៖ គេហៅមន្ទីរសិល្បៈភាគ?

រាម ៖ សិល្បៈភាគ ។ កាលនោះមានសិល្បៈតំបន់ សិល្បៈភាគ ។

ប៊ុនថន ៖ មីងឡើងមកតំបន់ ឡើងមកភាគ?

រាម ៖ ចា៎ បានមកភាគហើយ បានទៅតំបន់វិញ ។ មកតំបន់វិញ បានបែកយើងឡើងមកសិល្បៈមជ្ឈិមនៅនឹងភ្នំពេញ ។

ប៊ុនថន ៖ ទៅសិល្បៈភាគច្រើនទេ?

រាម ៖ អត់ទេ ទៅគ្នា៥នាក់ ប្រុសៗ៣នាក់ ស្រី២ ។

ប៊ុនថន :　មីងហើយនឹងពីណាទៀត មានចាំឈ្មោះទេ?

រាម :　មីនោះស្លាប់បាត់ហើយ ឈ្មោះ លាង ។

ប៊ុនថន :　ចុះប្រុសៗ?

រាម :　ប្រុសមាន៣នាក់ យ៉ាវ ដែលខ្ញុំថាអំបិញម៉ិញ រិន មួយ ហើយអីទេមួយទៀត ប៉ុន្តែពួកនោះឈឺសន្និស្លាប់អស់ហើយ ។

ប៊ុនថន :　គេរើសចេញតែម្តង?

រាម :　ចា៎ គេរើសឲ្យយើងទៅរៀន ដូចថា អាចក្តាប់ៗ ប្រុសពីរបីនាក់ គេក្តាប់ខាងភ្លេង ហើយម្នាក់ទៀតស្រីជាមួយខ្ញុំមិត្ត លាង គាត់ក្តាប់ខាងចម្រៀង ហើយខ្ញុំក្តាប់ខាងរបាំ ។

ប៊ុនថន :　មីងពូកែ ដូចថាអ្នកជ្រើសចេញទាល់តែអ្នកមើលទៅ...?

រាម :　គេអាចទុកចិត្តប្រើការកើត ។

ប៊ុនថន :　មើលទៅល្អជាងគេ សម្តែង?

រាម :　ចា៎ ។

ប៊ុនថន :　១០០នាក់ហ្នឹងរើសចេញតែ៥នាក់?

រាម :　តែ៥នាក់ ។ ខ្ញុំទៅហ្នឹងប្រហែលជាប់ពីរឆ្នាំ បានគេឲ្យខ្ញុំមកបង្ហាត់គេនៅតំបន់៣៥វិញមក ។

ប៊ុនថន :　មីងទៅសិល្បៈភាគជាមួយពីណា?

រាម :　ជាមួយ ធុច ។

ប៊ុនថន :　គាត់គ្រប់គ្រងនៅមន្ទីរនោះ?

រាម :　ចា៎ គាត់គ្រប់គ្រងសិល្បៈភូមិភាគ៣០៤ តែបន្ទាប់ពីគាត់មក មានឈ្មោះ ចន្ទ្រា ប្រុស ។ ប៉ុន្តែឥឡូវមិនដឹងទៅណាទៅណីទេ បែកគ្នាអស់ហើយ ។

ប៊ុនថន :　គាត់អនុប្រធាន?

រាម :　អនុប្រធាន ។

ប៊ុនថន :　ខាងសិល្បៈ?

រាម :　ចា៎ ។

ប៊ុនថន :　មន្ទីរសិល្បៈភាគនៅស្រុកណា?

រាម :　ដឹងតែនៅកំពង់ចាម ម៉ាដួរស្រុកចំការលើ ។

ប៊ុនថន :　អត់ដឹងភូមិទេ?

រាម ៖ អត់ដឹងភូមិទេ ព្រោះនៅក្នុងមន្ទីរ ព្រៃៗ នៅតំបន់៣៥ ក៏នៅក្នុងមន្ទីរ ក្នុងព្រៃ ហើយទៅនៅនោះក៏នៅក្នុងមន្ទីរក្នុងព្រៃដែរ ភូមិនៅឆ្ងាយៗ ។ ដល់ពេលយើងចេញចូលទៅសម្តែងបានយើងចូលដល់ភូមិ ។

ប៊ុនថន ៖ អ្នកមីងទៅដល់មន្ទីរភាគនោះគ្នាច្រើនទេ?

រាម ៖ ទៅគ្នា៥នាក់ ។

ប៊ុនថន ៖ ទៅដល់នោះ មានអ្នកនៅទីនោះទេ?

រាម ៖ នៅនោះច្រើនដែរ អគ្គភាពសិល្បៈគេ ។ នៅនោះប្រហែលជាប់ជាង១០០នាក់ ។ ប៉ុននៅកន្លែងនោះ ពេលតំនេរគេកាប់ដីលើករងដំឡូង គេដាំដំឡូង ។

ប៊ុនថន ៖ ក្រៅពីហាត់?

រាម ៖ បាទ ។ តែឲ្យវាយ៉ាប់យឺន ដូចជាមិនមានពេលយ៉ាប់ទេ ។

ប៊ុនថន ៖ ពីណាអ្នកបង្ហាត់មីង ទៅដល់ភាគ?

រាម ៖ ទៅភាគនោះ អ្នកនៅនោះ ពួក ធិ ។

ប៊ុនថន ៖ ឈ្មោះគាត់ ធិ?

រាម ៖ ធិ ប៉ុនបែកគ្នាអស់ហើយ ។

ប៊ុនថន ៖ ធិ ប្រធានមន្ទីរ?

រាម ៖ អ៊ើ ដូចជាមិនមែនប្រធានមន្ទីរទេ ដូចជាសមាជិក ។

ប៊ុនថន ៖ ប្រុស ឬក៏ស្រី?

រាម ៖ ស្រី ។

ប៊ុនថន ៖ គាត់ម្នាក់ហ្នឹងបង្ហាត់ទាំងអស់ដូចខាងច្រៀង...?

រាម ៖ គាត់ខាងរបាំ ។

ប៊ុនថន ៖ បង្ហាត់មីង?

រាម ៖ បាទ ។

ប៊ុនថន ៖ ចោះខាងច្រៀងសម្តែង?

រាម ៖ ខាងច្រៀងអត់មាននរណានៅទេ ។ មានដែរដូចថា អ្នកខាងច្រៀងខាងអី ប៉ុនបែកគ្នាអស់ហើយ ។ អ្នកនៅហ្នឹងអត់មានពីណាចូលមកនៅយើងទេ អត់មាន ។

ប៊ុនថន ៖ បែកទាំងអស់?

រាម ៖ បែកបាក់អស់ តែពួកខ្ញុំក៏អត់មានដែរ បែកអស់ ។

ប៊ុនថន ៖ មីងចេះពីនេះស្រាប់ ដល់ហាត់នៅនោះ?

រាម ៖ យើងចេះពីនេះខ្លះទៅ យើងចង់ក្តាប់របាំគេ ក្រែងគេនោះបានល្អៗជាងយើងនៅនេះ ។ ហើ យើងបានពីនោះល្អមកបង្ហាត់គេនៅទីនេះទៀត តៗគ្នា ។

ប៊ុនថន ៖ មីងបានចេញទៅសម្តែងទៀតទេពេលទៅភាគ?

រាម ៖ ទៅភាគនោះ ទៅសម្តែងហ្នឹងគេទៀតទៅ ចូលរួមរាំរបាំជាមួយគេទៀតទៅ ។

ប៊ុនថន ៖ សម្តែងពេលណា ពេលមានកម្មវិធី?

រាម ៖ ពេលធ្វើមីទ្ទិង គេបើកសន្និបាត ។

ប៊ុនថន ៖ ទៅកន្លែងណាខ្លះ?

រាម ៖ ទៅខាងនោះ ខ្ញុំអត់សូវចាំភូមិ អត់សូវស្គាល់ ។

ប៊ុនថន ៖ ច្រើនកន្លែងទេ?

រាម ៖ ច្រើនកន្លែង ។

ប៊ុនថន ៖ កំពង់ចាម?

រាម ៖ បាទ ដើរច្រើនកន្លែង ប៉ុនខ្ញុំអត់សូវចាំ ។

ប៊ុនថន ៖ មីទ្ទិងនោះ អ៊ីៗគាត់ចូលរួមដដែល ឬអ្នកផ្សេងៗទៀត?

រាម ៖ មានអ្នកផ្សេងៗ ប៉ុនអត់ស្គាល់គេ ។ ដូចអ៊ី ខៀវ សំផន អ៊ី អៀង សារី ទាល់តែធំ កម្មវិធីសំខាន់បានគាត់បើកមីទ្ទិង ឬសន្និបាតអីមួយចឹងទៅ ។ គាត់ចូលរួមនឹងយើង ។

ប៊ុនថន ៖ ប្រធានសិល្បៈដូចជា ធុច គាត់ដែលមកមើលសម្តែងទេ?

រាម ៖ មើល ដល់អីចឹងគាត់មកមើល ។

ប៊ុនថន ៖ ចុះមកមើលពេលហាត់?

រាម ៖ ចុះមកមើល ។

ប៊ុនថន ៖ គាត់អត់ចេះសិល្បៈទេ?

រាម ៖ គាត់អត់ចេះទេ ប៉ុនគាត់មកគ្រប់គ្រងភូមិភាគ៣០៤ ។ ភូមិភាគ៣០៤ វាធំដែរ មិនតូច ឯណា ម៉ាភូមិហ្នឹងនៅលើគាត់ទាំងអស់ ។

ប៊ុនថន ៖ កាលនោះ ធុច អាយុគាត់ប៉ុន្មាន?

រាម ៖ អាយុគាត់ច្រើនណាស់ គាត់ចាស់ហើយ ។ ម៉ាជំនាន់នោះអាយុគាត់ខ្ទង់៥០ គាត់ចាស់ ហើយ ចាស់ៗហើយ ។

ប៊ុនថន ៖ គាត់កាច ឬស្លូត?

រាម ៖ ទេ ដូចគាត់មិនសូវជាកាច បើតាមខ្ញុំធ្លាប់ស្គាល់គាត់ ។ មិនដែលឃើញបាបប្រជាជន ។

ប៊ុនថន ៖ ដូចថា ហាត់អីចឹង ដូនណាអ្នកធ្វើខុស អ្នកសម្តែង?

រាម ៖ អត់ដែលមានពាក្យសម្តី គាត់ប្រាប់ឲ្យយើងរៀនហាត់ឲ្យទន់ភ្លន់ ឲ្យស្អាត ល្មមម៉ាយើងចូលទៅអប់រំប្រជាជន ។ ឲ្យប្រជាជនជំនឿជឿជាក់មកលើយើង មានតែអីចឹង ។

ប៊ុនថន ៖ គាត់មិនដែលនិយាយលេងទេ?

រាម ៖ និយាយលេងធម្មតា ។

ប៊ុនថន ៖ មីងទៅនោះរយៈពេលប៉ុន្មាន បានមីងមកបង្ហាត់គេនៅនេះវិញ?

រាម ៖ ខ្ញុំទៅនៅនោះរយៈពេលប្រហែលពីរឆ្នាំ បានខ្ញុំបកមកតំបន់៣៥ នេះវិញមក ។

ប៊ុនថន ៖ ៣៥ចាស់?

រាម ៖ កន្លែងចាស់ ។

ប៊ុនថន ៖ ពេលមីងមក បងជីដូនមួយមីងគាត់នៅទេ?

រាម ៖ នៅហ្នឹង អត់មានទៅណាមកទេ ។ គាត់នៅតែខាងសិល្បៈនេះដែរ ។

ប៊ុនថន ៖ មីងមកជួបគាត់ និងមេចាស់ៗរបស់មីងនៅនេះដែរ?

រាម ៖ រាល់ថ្ងៃ!

ប៊ុនថន ៖ កាលនោះ?

រាម ៖ កាលនៅសម្តែង មេចាស់នៅហ្នឹងទាំងអស់ ជួបជុំគ្នា អត់មានបែកគ្នាទៅណាទេ ។

ប៊ុនថន ៖ ចោះមីងមកលែងសម្តែង បង្ហាត់គេម្តង?

រាម ៖ នៅនេះ!

ប៊ុនថន ៖ ពេលត្រឡប់មកពីកំពង់ចាម?

រាម ៖ នៅកំពង់ចាម មកវិញបង្ហាត់គេម្តង ។ មកបង្ហាត់នៅតំបន់៣៥ឲ្យគេចេះ ។

ប៊ុនថន ៖ មីងលែងចេញសម្តែង?

រាម ៖ សម្តែងដែរ របាំ ។

ប៊ុនថន ៖ បង្ហាត់គេផង សម្តែងផង?

រាម ៖ ចាំ៎ ហើយនឹងចេញខទ្ទេសនាម ។

ប៊ុនថន ៖ ចេញខទ្ទេសនាមម៉េច?

រាម ៖ យើងចេញផ្សាយ ផ្សាយជារបាំ ឬចម្រៀងអីឲ្យគេ ។

ប៊ុនថន ៖ ផ្សាយយ៉ាងម៉េច យើងដើរផ្សព្វផ្សាយ?

រាម ៖ យើងផ្សាយដូចយើងចេញសម្តែង យើងមិនចេញមកផ្សាយអារឿងចម្រៀងបទអីៗ របាំអីចឹងទេ ។

ប៊ុនថន ៖ ពិធីការ?

រាម ៖ ចា៎ ។

ប៊ុនថន ៖ ពេលមុនចេញយើងប្រាប់គេថាបទអី?

រាម ៖ ហ្នឹងហើយ ។ នៅសម័យនោះគេហៅយើងចេញខទ្វេសនាម ។

ប៊ុនថន ៖ មីងបង្ហាត់សិស្សប៉ុន្មាននាក់?

រាម ៖ ច្រើនដែរក្នុងអង្គភាពសិល្បៈ គ្រាន់តែអ្នករបាំជាប់គ្នាប្រហែលខ្ទង៣០នាក់ នឹងយើងគិតតែស្រីៗ បើទាំងប្រុសទាំងអីប្រហែលខ្ទង់៦០នាក់ ។

ប៊ុនថន ៖ ជិត១០០នាក់?

រាម ៖ ច្រើនដែរ ។

ប៊ុនថន ៖ ក្រុមសិល្បៈមានកំណត់អាយុទេ?

រាម ៖ អត់មានកំណត់ទេ ។ យើងរើសតែក្មេងៗចាប់ពីអាយុ១៥ ឬ១០ទៅបង្ហាត់បង្រៀន ។

ប៊ុនថន ៖ ពិបាកទេ?

រាម ៖ ពិបាកដែរ ទំរាំក្មេងៗចេះតាមយើង ស្តាប់យើង យ៉ាប់ដែរ ។

ប៊ុនថន ៖ មីងមកបង្ហាត់នៅតំបន់៣៥ប៉ុន្មានឆ្នាំ បានមីងទៅភ្នំពេញ ។

រាម ៖ មកយូរដែរ ទាំរាំយើងបែកភ្នំពេញ ១៧ មេសា ។ ដល់ពេលបែក គេឲ្យពួកសិល្បៈមកសម្តែងនៅអង្គរវត្តមួយអាទិត្យ ។ បានមួយអាទិត្យហើយ ត្រឡប់ទៅមន្ទីរវិញ បានគេជ្រើសរើសពួកខ្ញុំប៉ុន្មាន១០នាក់ មកសិល្បៈនៅភ្នំពេញ ។

ប៊ុនថន ៖ សម្តែង៧យប់នៅសៀមរាប អង្គរវត្ត?

រាម ៖ ៧យប់៧ថ្ងៃ ។ យើងសម្តែងទាំងយប់ទាំងថ្ងៃ

ប៊ុនថន ៖ មីងមានកម្លាំងសម្តែង ឬក៏ផ្លាស់វេនគ្នា?

រាម ៖ អត់ទេ សម្តែងអ្នកដដែល ប៉ុនខ្ចះក៏ងងុយដែរ ចេះតែស៊ូទៅ ។

ប៊ុនថន ៖ សម្តែងឲ្យពីណាមើល?

រាម ៖ ឲ្យពួកទ័ព ដែលយើងវាយបែក សម្តែងនៅអង្គរវត្ត ។

ប៊ុនថន ៖ ចុះមានភ្ញៀវអីផ្សេងទៀតទេ?

រាម ៖ មាន មានភ្ញៀវចិន ជប៉ុន គេចូលមើលច្រើន ។

ប៊ុនថន : សម្តែងក្នុងអង្គរវត្ត?

ភាម : សម្តែងក្នុងអង្គរ កន្លែងរានហាល កន្លែងល្មោនហ្លួងគេរាំថ្វាយស្តេចពីដើម ។

ប៊ុនថន : កន្លែងដុះដើមត្នោត?

ភាម : ហ្នឹងហើយ ។

ប៊ុនថន : គេសម្តែងពីអីខ្លះ?

ភាម : កាលនោះយើងសម្តែងពីវាយបែក១៧ មេសា យើងយកជ័យជម្នះបាន ។

ប៊ុនថន : អីៗមានមកមើលទេកាលនោះ?

ភាម : មក និយាយរួម ទៅសម្តែងកន្លែងណាក៏មានមុខគាត់ចូលរួមដែរ ។

ប៊ុនថន : សម្តែងដែលមានរង្វាន់ទេ?

ភាម : ជួនណាមាន គេជួយខត្តម្ព ។

ប៊ុនថន : ខត្តម្ពជាស្អី?

ភាម : មានស្អីទេ ដូចជាមេ្សា ក្រែម ខោអាវអីយើងរាំរែក ប្រដាប់ប្រដាសិល្បៈ ។

ប៊ុនថន : ភ្ញៀវ ឬមួយអីៗឲ្យ?

ភាម : អីៗ ភ្ញៀវនឹងដែរ ភាគភ្ញៀវ គេជិនួយជួយមក ។

ប៊ុនថន : អ្នកមីងរូបនេះថតនៅពេលណាមីង?

ភាម : អានេះខ្ញុំថតនៅឆ្នាំ៧២ អ្ហូមិនឆ្នាំ៧២ទេ ។ ឆ្នាំ៧៣ កាលខ្ញុំទៅសម្តែងនៅបន្ទាយស្រី ។

ប៊ុនថន : នេះនៅប្រាសាទបន្ទាយស្រី?

ភាម : ប្រាសាទបន្ទាយស្រី ។

ប៊ុនថន : កាលនោះទៅសម្តែងឆ្នាំ៧៣?

ភាម : ឆ្នាំ៧០ប៉ុន្មានដែរ ខ្ញុំមិនសូវចាំដែរ ។

ប៊ុនថន : កាលនោះមីងដើរទៅ?

ភាម : ដើរទៅ ។ ទៅវាជិតដែរ មិនឆ្ងាយប៉ុន្មានទេ ។

ប៊ុនថន : ពីជីក្រែងទៅបន្ទាយស្រី ប៉ុន្មានគីឡូ?

ភាម : ឆ្ងាយដែរ ។ ដើរឡើងមួយព្រឹក ហើយថ្ងៃណាណីបានដល់ ។

ប៊ុនថន : ប៉ុន្មាននាក់កាលមួយក្រុមមីងទៅនោះ?

ភាម : មួយក្រុមច្រើនដែរ សុទ្ធតែពួកសិល្បៈទាំងអស់ ។

ប៊ុនថន : ៥០-៦០នាក់?

ភាម :	ចាំ ។

ប៊ុនថន :	ទៅសម្តែងឲ្យខាងណាមើល?

ភាម :	កាលនោះយើងសម្តែងឲ្យប្រជាជន លើកទំនប់លើកអី ។

ប៊ុនថន :	លើកទំនប់?

ភាម :	គេជីកប្រឡាយជីកប្រឡាយនៅបន្ទាយស្រី ហើយមានទ័ពគេចូលរួមក្នុងហ្នឹង ។ និយាយរួមទៅ ពេលយើងទៅសម្តែងនៅកន្លែងណា គឺមានប្រជាជននៅកន្លែងហ្នឹង ហើយនឹងទ័ពគេការពារជាប់ ។

ប៊ុនថន :	ការពារក្រុមសិល្បៈ?

ភាម :	ការពារក្រុមសិល្បៈ ការពារប្រជាជនយើង ។ ឧទាហរណ៍ ពេលសម្តែងទៅ វាមានខ្មាំងឡើងអុកឡុកអីចឹងទៅ គេមានដាក់ខ្សែត្រៀមគេការពារជាប់ អត់មានប្រហែសទេ ។ ឲ្យតែធ្វើមីទ្ទីងគឺមានហើយ ការពារជាប់រហូត ។

ប៊ុនថន :	កាលនោះនរណាដឹកនាំទៅសម្តែង?

ភាម :	ពូ មុញ ។

ប៊ុនថន :	គាត់មានរូបថតនៅក្នុងនេះទេ?

ភាម :	អត់ អត់ឃើញគាត់ផង ។ គាត់កម្រថតចូលជាមួយផង ។

ប៊ុនថន :	សម្តែងរយៈពេលប៉ុន្មាននៅបន្ទាយស្រី?

ភាម :	បន្ទាយស្រី សម្តែងពីរយប់ពីរថ្ងៃ ។

ប៊ុនថន :	សម្តែងនៅក្នុងប្រាសាទ?

ភាម :	នៅកៀនប្រាសាទ គេធ្វើឆាក ។ អត់មាននៅក្នុងបន្ទាយស្រីទេ គេធ្វើឆាកនៅក្រោយបន្ទាយស្រី ។

ប៊ុនថន :	ក្រោយប្រាសាទបន្ទាយស្រី?

ភាម :	បាទ ។

ប៊ុនថន :	ស្នាក់នៅណា?

ភាម :	ស្នាក់នៅតាមផ្ទះប្រជាជន ។

ប៊ុនថន :	សម្តែងតែពេលយប់?

ភាម :	តែពេលយប់ អត់មានសម្តែងថ្ងៃទេ ។

ប៊ុនថន :	ចុះមានម៉ាស៊ីន មានភ្លើងទេ?

រាម ៖ មានភ្លើងគេដាក់អំពូលម៉ែត ។ ដូចយើងធម្មតារាល់ថ្ងៃហ្នឹង គេដាក់អំពូលម៉ែត ដាក់ភ្លឺចាចពេញហ្នឹង ។

ប៊ុនថន ៖ ដាក់មេក្រូទេ?

រាម ៖ ដាក់មេក្រូអីទាំងអស់ ។

ប៊ុនថន ៖ ភ្លេង?

រាម ៖ ភ្លេងមានប្រើប្រាស់ មានគ្រប់ភ្លេងទាំងអស់ម៉ាខបករណ៍ ។ មានទ្រ មានកុលអុង អត់តែព្យាណូដែលយើងយកទៅមិនរួចទេ វាឆ្ងាយ ។ មានរបស់ណាតូចៗដែលយើងស្ពាយទៅរួច ។

ប៊ុនថន ៖ ព្យាណូ?

រាម ៖ ព្យាណូអត់មានទេ ។

ប៊ុនថន ៖ អត់យកទៅ?

រាម ៖ អត់មានតែម្តង ទោះបីយកទៅ ទោះបីមានក៏យើងយកទៅមិនរួច ។ បើយើងស្ពាយជាប់នៅនឹងខ្លួន ភាគច្រើនគឺយើងស្ពាយ ។

ប៊ុនថន ៖ អ្នកណាកាន់ខាងហ្នឹង ស្ពាយខាងហ្នឹង?

រាម ៖ ចា៎ អ្នកណាកាន់ខាងហ្នឹង ស្ពាយអាហ្នឹងទៅ ។

ប៊ុនថន ៖ មីងបានថតច្រើនកន្លែងទេ?

រាម ៖ ទៅកន្លែងណាក៏ថតដែរ ។ រូបថតច្រើនណាស់ ប៉ុន្តែខ្ញុំម៉ាឆុល យួនដេញបាញ់ដេញអីនេះរត់ប្រកិតប្រភីងគេព័ទ្ធចាប់ រកយកមិនបាន ។ ខ្ញុំរត់យកតែព្រះអាយុ ក្រវាត់ចោលតាមទឹកអីផង ។

ប៊ុនថន ៖ កាលនោះមានថតតែងទេ?

រាម ៖ មាន ថតតែងថតអីមាន ស្លៀកខោអាវពណ៌ ។

ប៊ុនថន ៖ នរណាអ្នកតែង?

រាម ៖ កាលនោះ ពេលយើងទៅសម្តែងម៉ាកន្លែងៗមាន គេអ្នកជាងថតផ្សឹង តាមតំបន់ ។ ឧទាហរណថា យើងទៅសម្តែងនៅម៉ាឡៃអីចឹង មានកន្លែងគេចាំថតផ្សឹង ។

ប៊ុនថន ៖ មានអ្នកចាំថតដើរតាមក្រុមសិល្បៈ?

រាម ៖ អត់មានទេ ។ ពួកក្រុមសិល្បៈអត់មានអ្នកចាំខាងជំនាញថតនោះអត់មានទេមានឧទាហរណ៍ដូចថាពួកកាសែត ។

ប៊ុនថន ៖ ចោះនេះមានចាំថាអ្នកណាថតទេ?

រាម ៖ ថតចាំទេ អត់ស្គាល់គេ ភាគច្រើនអត់ស្គាល់គេ ចេះតែថត ។

ប៊ុនថន ៖ ចោះកាលនោះមីងអត់ដែលបានមើលទេ ពេលសម្ដែងថតនោះ ទើបនឹងឃើញក្រោយ?

រាម ៖ អត់ទេរូបថតពួកខ្ញុំមានដែរ ប៉ុនក្រវាត់ចោលអស់ ។

ប៊ុនថន ៖ គេថតឲ្យម្នាក់មួយសន្លឹក?

រាម ៖ អត់ទេ គេថតហើយផ្ដិត ផ្ដិតបានហើយ គេផ្ញើមកយើង ។ យើងមើលហើយទុកទៅ អ្នកណាចង់បានទុកទៅ ។

ប៊ុនថន ៖ ផ្ញើមកមន្ទីរ?

រាម ៖ គេផ្ញើមកមន្ទីរ ចង់ស្គាល់រូបខ្លួនឯងអីចឹង ។

ប៊ុនថន ៖ នេះប្រធានគេរៀបចំឲ្យថត?

រាម ៖ ហ្នឹងប្រធានយើងហ្នឹងហើយ រៀបចំឲ្យថត គេចង់បាន គេរៀបចំឲ្យយើងអង្គុយថត ប៉ុន្តែគាត់មិនបានចូលរួមទេដូចថា គាត់ជាប់រវល់ គាត់ប្រាប់អនុឲ្យរៀបឲ្យ ។

ប៊ុនថន ៖ ប៉ុនក្រៅពីថតកន្លែងហ្នឹង មីងថតកន្លែងផ្សេងដែលរៀបចំថតទេ?

រាម ៖ មាន មានកន្លែងផ្សេងទៀត តែបាត់ប៉ុន្មានកន្លែងទៀត អត់ឃើញមានទេ ។

ប៊ុនថន ៖ ឃើញរូបថតមួយទៀត ថតតែស្រីសុទ្ធតែម្ដង?

រាម ៖ បាទ ថតស្រីៗសុទ្ធ ។

ប៊ុនថន ៖ នៅខាងណាទេ ខ្ញុំផ្ដិតរូបមួយធំដែរ?

រាម ៖ អាហ្នឹង សៀវភៅហ្នឹងគេយកមកឲ្យខ្ញុំមើលម្ដងហើយ ឃើញមានសុទ្ធតែស្រី តែមិនដឹងជានៅចន្លោះណា ។

ប៊ុនថន ៖ រូបថតនេះពាក់ក្រម៉ាទាំងអស់?

រាម ៖ សុទ្ធតែអីចឹង ដើរទៅណាម៉ាឈុតគេហ្នឹង ប្រើតែអីចឹង ។ ដាក់ឈុតគេទាំងអស់គ្នា ច្រើនតែ អីចឹងឯង ។

ប៊ុនថន ៖ មីងមានចាំមុខខ្លះទេស្រីៗ?

រាម ៖ អត់ចាំទេ មើលគេមិនស្គាល់ មើលគេយូរទៅវាបែកផ្សែងភ្នែក មិនសូវចាំទេ ។ តែថ្ងៃហ្នឹងអាណានវាទៅរៀន វាយកមកឲ្យមើលទៅ ខ្ញុំពាក់វ៉ែនតាទៅក៏បានស្គាល់ម្នាក់ ។ និយាយរួមទៅបែកគ្នាយូរពេក មិនសូវចាំឈ្មោះចាំអី ។ បែកគ្នាចង់អស់ ចាំបានតែប្រធានៗ ។

ប៊ុនថន ៖ ថតនេះឆ្នាំ៧៣?

រាម ៖ បាទ ។

ប៊ុនថន ៖ ចេញពីសៀមរាប មីងឡើងមកសិល្បៈមជ្ឈិម?

រាម ៖ ចាំ ។

ប៊ុនថន ៖ មកប៉ុន្មាននាក់?

រាម ៖ មកគ្នា១០នាក់នៅសិល្បៈមជ្ឈិម ប្រុស៥ ស្រី៥ ។

ប៊ុនថន ៖ មីងមានចាំឈ្មោះប្រុសៗទេ?

រាម ៖ វាបែកគ្នាអស់ទៀតទៅ ។

ប៊ុនថន ៖ មីងនៅចាំប៉ុន្មាននាក់?

រាម ៖ មានឈ្មោះ ពូអួន ពូរិន ។ ណាខ្លះទេ ដល់បែក ខ្ញុំភ្លេចឈ្មោះគេអស់ ។

ប៊ុនថន ៖ ចោះស្រីៗ?

រាម ៖ ស្រីៗមានឈ្មោះមិត្ត វ៉ាន់ ឈ្មោះមិត្ត លាង ហើយនឹងខ្ញុំ ហើយ រិន ហើយនិង វ៉ែន ។

ប៊ុនថន ៖ សព្វថ្ងៃមីនអត់ដែលជួបទេ?

រាម ៖ អត់ដែលទេ ។

ប៊ុនថន ៖ បែកទាំងអស់?

រាម ៖ បែកគ្នាអស់ ។

ប៊ុនថន ៖ មីងមកភាគហ្នឹង នៅខាងណាភ្នំពេញ?

រាម ៖ នៅភ្នំពេញ!

ប៊ុនថន ៖ បាទ?

រាម ៖ នៅភ្នំពេញ កាលនោះគេហៅសិល្បៈមជ្ឈិម នៅមហោស្រព ។ យើងតែងសម្តែងនៅក្នុង មហោស្រព ស្តាត ។ ពេលគេធ្វើមីទ្ទីងទៅ គេឲ្យពួកខ្ញុំមកសម្តែងនៅកន្លែងប៉ុស្តិ៍ ។

ប៊ុនថន ៖ នៅកន្លែងណាមានចាំទេ?

រាម ៖ នៅកន្លែងស្ទូឌីយោយើងផ្សាយ ។

ប៊ុនថន ៖ កន្លែង?

រាម ៖ ស្ទឹងមានជ័យ ។

ប៊ុនថន ៖ នៅជាមួយពីណា?

ភម ៖ កាលនោះយើងផ្លាស់មេទៀត ។ ផ្លាស់អ្នកគ្រប់គ្រង នៅជាមួយ ហ៊ូ នឹម ។ តា ហ៊ូ នឹម គេចាប់គាត់យកទៅវាយចោល ។

ប៊ុនថន ៖ តាំងពីមីងនៅទីនោះ?

ភម ៖ ចាំ ។

ប៊ុនថន ៖ ប៉ុន្មាននៅសិល្បៈមជ្ឈិម?

ភម ៖ ទៅ១០នាក់ ។

ប៊ុនថន ៖ ទៅដល់នោះ?

ភម ៖ តែ១០នាក់ គេជ្រើសរើសយកតែ១០នាក់គត់ ។

ប៊ុនថន ៖ មានអ្នកនៅទីនោះស្រាប់ទេ?

ភម ៖ មានគ្នាច្រើន រើសបញ្ចូលគ្នាតាំងពីភូមិភាគ៣០៤ បញ្ចូលគ្នានៅហ្នឹង ។

ប៊ុនថន ៖ ទាំងអស់ប៉ុន្មាននាក់សិល្បៈមជ្ឈិម?

ភម ៖ សិល្បៈមជ្ឈិមនេះគ្នាច្រើនដែរ ទាំងអ្នកភ្លេង ទាំងអ្នករបាំ ទាំងអ្នកចម្រៀង ច្រើនដែរនៅអង្គភាពហ្នឹង ។

ប៊ុនថន ៖ ចោះ ធុច គាត់លែងគ្រប់គ្រង?

ភម ៖ គាត់លែងហើយ នៅតែអឹទេ គាត់គ្រប់គ្រងនៅហ្នឹង អឺ ហ៊ូ នឹម ។

ប៊ុនថន ៖ ទៅដល់នោះមានគេបែងចែកក្រុមផ្សេងៗដូចជាក្រុមចម្រៀង?

ភម ៖ មានអ្នកចម្រៀង មានអ្នកភ្លេង មានអ្នកលេងរឿង បង្ហាត់តាមផ្នែកគ្នាទាំងអស់ ។

ប៊ុនថន ៖ ក្រុមវិទ្យុផ្សាយមានទេ?

ភម ៖ មាន ។

ប៊ុនថន ៖ ក្រុមគេផ្សេង?

ភម ៖ ចាំ អង្គភាពគេផ្សេង ប៉ុននៅជាមួយគ្នា រស់នៅជាមួយគ្នា ម៉ាជុំគ្នាឯងទាំងអស់ ។ ម៉ាអង្គភាពយើងនៅជាមួយ ដេកនៅផ្ទះជាមួយគ្នា ។

ប៊ុនថន ៖ បទចម្រៀងពីណាអ្នកច្រៀងដូចថាពូកែ?

ភម ៖ ពូកែច្រៀងពួក ពេជ្រ គាត់ច្រៀងពិរោះណាស់ ។

ប៊ុនថន ៖ ស្រី ឬប្រុស?

ភម ៖ ស្រី តែខ្មោ មាឌទាប តែឥឡូវមិនដឹងទៅណាទៅណីទេ ។

ប៊ុនថន ៖ ចុះមានបទគាត់ច្រៀងទេ ដូចថាថតទុក?

រាម ៖ អត់មានទេ ។ ចម្រៀងម៉ាជំនាន់ហ្នឹងអត់ដែលឃើញមានទេ ។

ប៊ុនថន ៖ ដូចជាបទ១៧ មេសា?

រាម ៖ ចា៎ គាត់ច្រៀងបទហ្នឹងឯង ។

ប៊ុនថន ៖ បទ១៧មេសាគាត់អ្នកច្រៀង?

រាម ៖ ចា៎ ឈ្មោះ ពេជ្រ អ្នកច្រៀង ។ ប៉ុនដល់ឥឡូវវាមិនដឹងទៅណាទៅណីអស់ ។ ហើយ ឈ្មោះ ពេជ្រ មិនដឹងទៅណាទៅណីអស់ រត់ទីវណាត់ទីវណែង ។

ប៊ុនថន ៖ គាត់ច្រៀងច្រើនបទទេ?

រាម ៖ គាត់ច្រៀងច្រើនណាស់ព្រោះសម្លេងគាត់បាន ។

ប៊ុនថន ៖ ចុះប្រុសៗពីណា?

រាម ៖ ប្រុសៗ នរណាខ្លះទេ ។ ប្រុសច្រើនដែរ អ្នកចម្រៀងនោះ ភ្លេចឈ្មោះអស់ហើយ ។

ប៊ុនថន ៖ អ្នកល្បីដូចជា ស៊ីន ស៊ីសាមុត ដូចថាល្បីច្រៀងបទបដិវត្តន៍?

រាម ៖ មានច្រើនដែរ ដូចថា វ៉ាតៗ នោះក៏ច្រៀងពិរោះដែរ ។

ប៊ុនថន ៖ ស្អី វ៉ាត?

រាម ៖ ខ្ញុំភ្លាប់នាមត្រកូលគេមិនបាន ស្អី វ៉ាត ប្រុស នោះក៏ច្រៀងពិរោះដែរ ។ សម្លេងគេបាន ដែរនោះ ។

ប៊ុនថន ៖ គាត់ខស្សរ្រាហ៍ឡើងច្រៀងទេ?

រាម ៖ ឲ្យតែទៅសម្តែងកន្លែងណា គាត់ឡើងច្រៀងគ្រប់តែបទ សម្លេងគេបាន ។

ប៊ុនថន ៖ វ៉ាត ស្រុកគេនៅណា?

រាម ៖ នៅខាងបូព៌ា ។

ប៊ុនថន ៖ បើ ពេជ្រ មានស្គាល់ច្បាស់?

រាម ៖ ពេជ្រ នៅខាងកំពង់ធំ ។

ប៊ុនថន ៖ ស្រុកកំណើតនៅកំពង់ធំ?

រាម ៖ បាទ កំពង់ធំ នោះច្រៀងពិរោះណាស់ សម្លេងបានចង់ប្រហែល រស់ សេរីសុទ្ធា ដែរ ។ ស៊ីគ្នានឹង ប៉ែន រ៉ន ដែរ ចង់ប្រហាក់ប្រហែលគ្នា ។

ប៊ុនថន ៖ ឈ្មោះស្អី ពេជ្រ មីង?

រាម ៖ ត្រកូលខ្ញុំអត់ស្គាល់ទេ ប៉ុនឈ្មោះវា ពេជ្រៗ ច្រៀងពិរោះណាស់ ។

ប៊ុនថន ៖ គាត់ម៉ាជំនាន់មីង ឬទៅមុន?

រាម ៖ អត់ទេ ម៉ាជិនាន់ខ្ញុំ ។

ប៊ុនថន ៖ រើសពី?

រាម ៖ ពីតំបន់៣៥ទៅ ។

ប៊ុនថន ៖ ប៉ុននៅកងជាមួយមីងទេ ទៅដល់ភ្នំពេញបានជួបគ្នា?

រាម ៖ នៅជាមួយគ្នាតំបន់៣៥ រើសពីតំបន់៣៥យកទៅភ្នំពេញ ។

ប៊ុនថន ៖ នៅជាមួយគ្នា?

រាម ៖ បាទ សម្លេងវាពិរោះណាស់ ហើយឈ្មោះមី ម៉ៃៗ នោះក៏ច្រៀងពិរោះដែរ ពិរោះហើយ មីហ្នឹង ។ មីហ្នឹងច្រៀងតាំងពីបទសង្គមចាស់ លលកញីឈ្មោល ហ្នឹងវាច្រៀងពីសង្គម ។ ច្រៀងបទហ្នឹង ដល់ចូលមកច្រៀងជាមួយខ្មែរក្រហមច្រៀងទៀត ហ្នឹងឈ្មោះតា ធុចៗ យកគាត់តាមជាប់ ។

ប៊ុនថន ៖ គាត់ស្អាតទេ?

រាម ៖ ឈ្មោះមី ម៉ៃ នោះស្អាត់ណាស់ ហើយចម្រៀងវា សម្លេងវាបានពិរោះណាស់ ។

ប៊ុនថន ៖ គាត់ដើរតាម?

រាម ៖ តាមតា ធុច ។

ប៊ុនថន ៖ ចោះមកនេះហើយក៏គាត់ដើរតាមតា ធុច ដែរ?

រាម ៖ នៅដើរតាមរបូត តែដល់ពេលយើងរត់បែកទៅទៀតទៅ មិនដឹងទៅណាទៅណីទេ ។ បែកគ្នាទាំងអស់ ម៉ាអង្គភាពសិល្បៈហ្នឹងរត់បែកគ្នាទាំអស់ ។ ពេលយួនចូលដល់ភ្នំពេញ ដល់ហើយយើងរត់ត្រគាក់ប្រទាន់ យកព្រះអាយុរៀងខ្លួន មិនដឹងអាណាទៅណីទៅណាខ្លះ ។ ខ្ញុំរត់បែកពីគេតាមគ្នាបានបីនាក់ ដើររបូត មិនដែលមានឡានជិះទេ ខ្ញុំចេញពីភ្នំពេញមក ខ្ញុំដើររបូតរហូតទៅដល់ព្រំដែន ។

ប៊ុនថន ៖ នារីម៉ៃឡើងទៅសិល្បៈមជ្ឈិមដែរ?

រាម ៖ ទៅជាមួយគ្នានៅភ្នំពេញដែរ នៅសិល្បៈមជ្ឈិមដែរ ។

ប៊ុនថន ៖ ប៉ុនគាត់នៅជាប់ជាមួយតា ធុច អត់នៅជាមួយ ហ៊ូ នឹម ទេ?

រាម ៖ កាលនោះ នៅជាប់ជាមួយតា ធុច គាត់នៅភូមិភាគ៣០៤ នឹងជាប់ ។ ដល់ក្រោយមកទៀតមក ផ្លាស់ពីតា ធុច មកនៅអង្គភាពជាមួយពួកខ្ញុំ ហ៊ូ នឹម គាត់គ្រប់គ្រង់ ព្រោះអីសិល្បៈតំបន់៣៥ និងភូមិភាគ៣០៤ គេរំសាយអស់ហើយ ។ អត់មាននៅទេ រំសាយចូលនៅសិល្បៈមជ្ឈិមនេះអស់ នៅភ្នំពេញអស់ទៅ ។

ប៊ុនថន : ចោះមាននៅបទចម្រៀងគាត់ទេ នៅចាំទេ?

រាម : អត់ចាំទេ។ បង ម៉ែ!

ប៊ុនថន : បាទ កាលបីឆ្នាំមានច្រើនដូចជា បទ ១៧ មេសា បទនារីស្រែអំបិល?

រាម : នារីស្រែអំបិល ស្រែអីសុទ្ធតែគាត់ច្រៀងហើយ បងម៉ែ ហើយនិង ពេជ្រ គាត់ច្រៀង។

ប៊ុនថន : មីងចាំសម្លេងទេរាល់ថ្ងៃនេះ?

រាម : អត់ទេ បើថាស្តាប់សម្លេងម៉ាជំនាន់ពួកនោះច្រៀង ខ្ញុំនៅស្តាប់បាន នៅចាំបាន។

ប៊ុនថន : ឈ្មោះអ្នកណាៗ?

រាម : ចាំ ប៊ុនយើងឥឡូវដូចមិនដែលឃើញមានទេ មិនដែលឮសូរនរណាគេចាក់។

ប៊ុនថន : អត់អីទេ ខ្ញុំមាន ចាំមើលយកឲ្យមីងស្តាប់។ ដូចថា មានប្រុសមានស្រី មីងអាចចំណាំបានទេ?

រាម : សម្លេងចំណាំបានខ្លះ បើប្រុសច្រៀង ស្រីក៏ចំណាំបាន។ ប៊ុនខ្ញុំរកនឹកអាឈ្មោះគេច្រៀងនោះវាភ្លេចអស់ទៅ រត់បែកគ្នាអស់ទៅមិនសូវចាំ។

ប៊ុនថន : នៅសិល្បៈមជ្ឈិមនោះ មីងមានដើរសម្តែងទៀតទេ?

រាម : នៅសិល្បៈមជ្ឈិម ដើរសម្តែងបានច្រើនណាស់។ ទៅតាមភូមិភាគ យើងដើរសម្តែងបានច្រើនដែរ។

ប៊ុនថន : ទៅភូមិភាគណាខ្លះ?

រាម : មើលទៅនៅកន្លែងសិល្បៈមជ្ឈិម ខ្ញុំទៅសម្តែងខាងកំពង់សោម ហីទៅខាងកំពង់ចាម ហីទៅខាងនិរតី។ ដើរបានច្រើនដែរ ប៊ុនដឹងកន្លែងណាកន្លែងណីទេ ច្រើនណាស់។ ចាំមិនអស់ដែរ មិនចេះតិចកន្លែង ថានៅនឹងក្រសួងភាគតិចណាស់ ភាគច្រើនចេញទៅសម្តែង។

ប៊ុនថន : សម្តែងម្តងរយៈពេលប៉ុន្មាន?

រាម : ដូនណាកន្លះខែទៅមួយខែ បានត្រឡប់ចូលកន្លែងវិញ។

ប៊ុនថន : ទៅម្តងៗ លែងដើរទៀតហើយ ជិះឡានទៅ?

រាម : កាលនោះយើងវាយបែកភ្នំពេញ មកនៅមជ្ឈិមយើងអត់ដែលដើរទេ ជិះតែឡាន។

ប៊ុនថន : ឡានដូនទៅ?

រាម : ចាំ ឡានដូនទៅរបូត ឡានពីរគ្រឿង ដឹកសម្ភារៈមួយឡាន ដឹកមនុស្សមួយឡាន។ ប៊ុនភាគច្រើនមិនដែលបានចេញទៅណាទេ តិចៗភ្ញៀវមក យើងទៅសម្តែងនៅមហោស្រពស្តាតៗ។

ប៊ុនថន ៖ មហោស្រពនៅជាប់មាត់ទន្លេ?

រាម ៖ ជាប់មាត់ទន្លេ ។

ប៊ុនថន ៖ សាលរាំងកោង?

រាម ៖ ចា៎ ។

ប៊ុនថន ៖ ភាគច្រើនភ្ញៀវណា?

រាម ៖ ភ្ញៀវច្រើនណាស់ ។

ប៊ុនថន ៖ មកពីណាខ្លះ?

រាម ៖ តាំងពីកូរ៉េ តាំងពីជប៉ុន តាំងពីអាមេរិក តាំងពីអាហ្វ្រិក ច្រើនដឹងមកពីណាខ្លះ ។ ជូនណាមួយអាទិត្យពីរអាទិត្យជាប់គ្នារដឹក ខានយ៉ាច្រើន មួយអាទិត្យមួយថ្ងៃទេ បន្តិចភ្ញៀវមកទៀត ។

ប៊ុនថន ៖ ខាងខ្មែរយើងអ្នកធំមានទៅទេ?

រាម ៖ អ្នកមានទៅដែរ អ៊ឹ ខៀវ សំផន អ៊ឹ អៀង សារី កន្លែងអ៊ឹ នួន ជា តាពត គាត់ទៅចូលរួម ហើយដូចជា ហ៊ូ នឹម សុទ្ធតែមេធំៗ មេទ័ពអីនោះ ។

ប៊ុនថន ៖ មានហាត់សមទេមុននឹងសម្ដែង?

រាម ៖ យើងហាត់ ។ ដូចថា ស្អែកភ្ញៀវមក ថ្ងៃនេះយើងចាប់ផ្ដើមហាត់ ។ ព្រលឹមឡើងយើងហាត់ទៀតទៅ ទំរាំដល់ម៉ោងយើងសម្ដែង ។

ប៊ុនថន ៖ អ្នកដឹកនាំក្រុមពីណា?

រាម ៖ កាលនោះឈ្មោះបង ថា ។

ប៊ុនថន ៖ ឈ្មោះស្អីថា?

រាម ៖ ស្ដាប់នាមត្រកូលគេអត់បានទេ ដឹងតែឈ្មោះគេទទេៗ ឈ្មោះពូ ទ្រា ។

ប៊ុនថន ៖ ថា ហ្នឹងស្រី?

រាម ៖ ថា ហ្នឹងស្រី ទ្រា នោះប្រុស ។ ដូចថាគាត់គ្រប់គ្រងបន្ទាប់ពីក្រសួងហ្នឹងមក សាខា គេដឹកនាំទទួលខុសត្រូវបន្ទាប់មក ។

ប៊ុនថន ៖ ស្រុកកំណើតគាត់នៅណា ថា?

រាម ៖ បង ថា ស្រុកកំណើតនៅកំពង់ចាម ហើយ ទ្រា នៅខាងបូព៌ា ។

ប៊ុនថន ៖ សម្ដែងឲ្យអ្នកធំមើល មិនភ័យទេ?

រាម ៖ ធម្មតា ដូចថាធ្លាប់ហើយ ។

ប៊ុនថន ៖ សម្តែងរបាំមានអីខ្លះឲ្យភ្ញៀវមើល?

រាម ៖ កម្មវិធីយើងច្រើនតែរបាំ ម៉ាស្រុករនេះយើងច្រើនមានរបាំគោះត្រឡោក របាំក្រាប់ របាំត្រុដិ ។

ប៊ុនថន ៖ អត់មានរបាំបាចផ្កា?

រាម ៖ មាន ដូចរបាំយើងសព្វថ្ងៃមានទាំងអស់ គេរាំជូនពរ ។

ប៊ុនថន ៖ យើងពាក់ខោអាវអី?

រាម ៖ ខោអាវយើងស្លៀកសំពត់ចងក្បិន ។

ប៊ុនថន ៖ ដូចសព្វថ្ងៃ?

រាម ៖ ចាំ ដូចសព្វថ្ងៃ ។

ប៊ុនថន ៖ អត់មានស្លៀកពាក់ខោអាវចិនទេ?

រាម ៖ អាចេះៗគេលែងត្រូវការហើយ ឈប់ត្រូវការទាំងអស់ ប្រើខោអាវពណ៌ទាំងអស់ ។

ប៊ុនថន ៖ ពេលភ្ញៀវមកស្លៀកខោអាវពណ៌?

រាម ៖ ចាំ ។

ប៊ុនថន ៖ លាយចម្រុះគ្នា?

រាម ៖ ចាំ អត់មានខោអាវនេះទៀតទេ ខោអាវនេះគេឈប់ប្រើហើយ ។ គេចម្រុះពណ៌គ្នា ដូចថាពណ៌មួយគួរចឹងទៅ មានពណ៌ក្រហម ពណ៌បៃតង តែយើងរាំរបាំជូនពរមានស្លៀកសំពត់ចងក្បិនដូចយើងសម្តែង ។

ប៊ុនថន ៖ មានមួក ពាក់មុដទេ?

រាម ៖ តែអត់មុដិទេ គ្រាន់តែយើងតុបតែងជាខ្លួន ម៉ាជំនាន់នោះយើងអត់ទាន់មានមុដិមានអីទេ ។ គ្រាន់តែយើងមានខោអាវដូចគ្នាដែរ គេធ្វើឲ្យយើងបាន ប៉ុនមិនទាន់ជាមុដិជាអីទេ ។ ដូចថាមេធំអី ជូនណាទៅ សីហនុ គាត់មកទស្សនកិច្ច យើងច្រៀងបទហ្នឹង រាំបទហ្នឹងថ្វាយគាត់ ។

ប៊ុនថន ៖ គាត់ដែលមកទស្សនកិច្ចដែរ?

រាម ៖ មាន ។

ប៊ុនថន ៖ នៅណា?

រាម ៖ នៅភ្នំពេញ ។

ប៊ុនថន ៖ កន្លែងមហោស្រព?

រាម ៖ ចាំ ៗ

ប៊ុនថន ៖ ជាប់មាត់ទន្លេ?

រាម ៖ ហ្នឹងឯង ស្អាត ៗ គាត់មកទស្សនកិច្ចម្ដង១ យើងរាំថ្វាយគាត់ ៗ មិនថា សីហនុ សូម្បីនៅនេះយើងថាសង្គ្រាមនៅតែគាត់យាងមកទស្សនកិច្ចនៅនេះដែរ ៗ

ប៊ុនថន ៖ នៅនេះមីងសិល្បៈដែរ?

រាម ៖ ចាំ ៗ

ប៊ុនថន ៖ មីងរាំថ្វាយគាត់?

រាម ៖ ចាំ ៗ បទហ្នឹងដដែល បទជូនពរ បទបាចផ្កា គ្រាន់តែយើងអត់មានម្កុដិ ៗ

ប៊ុនថន ៖ នៅភ្នំពេញស្ដេចយាងមកមើលច្រើនដងទេ?

រាម ៖ ចាំនៅភ្នំពេញគាត់មក ៗ

ប៊ុនថន ៖ ប៉ុន្មានដង?

រាម ៖ បី-បួនដង ៗ បើមកនេះ គាត់យាងមកបានពីដង ៗ កាលគាត់យាងមកនេះ ទឹកទន្លេឡើងទៀត ប៉ុនមានជិះរឺចម្លងគាត់ពីទឹកមក ជិះរឺចម្លងទឹក កាលនោះទឹកឡើងមកជន់ខ្លាំង ៗ ពួកខ្ញុំឈរទទួលគាត់ទឹកត្រឹម១ណោះ ៗ

ប៊ុនថន ៖ ឈរក្នុងទឹក?

រាម ៖ ចាំចូលមកនៅក្នុងមន្ទីរ ៗ

ប៊ុនថន ៖ មីងសម្ដែងរហូតដល់បែក?

រាម ៖ ចាំសម្ដែងរហូតដល់បែក ភ្ញៀវច្រើនណាស់ ៗ កាលមុននៅភូមិដូងក៏មានអគ្គភាពសិល្បៈដែរ តែគេទើបនឹងបែកគ្នាអស់ គេរំសាយចេញអស់ ៗ

ប៊ុនថន ៖ មីងនៅជាមួយ ហ៊ូ នឹម យូរទេបានបាត់គាត់?

រាម ៖ នៅប្រហែលជាយូរដែរ មើលកាលពីយើងវាយបែក៧៥ ១៧ មេសា មក ខ្ញុំនៅជួបគាត់រហូត ៗ បានប្រហែលឆ្នាំ១៩៧៧ បានគេចាប់ផ្ដើមចាប់គាត់ទៅ ៗ

ប៊ុនថន ៖ ម៉េចបានជាគេចាប់គាត់?

រាម ៖ អត់ដឹងដែរ ៗ ខ្ញុំដឹងតែពេលចាប់គាត់ទៅ ពេលវេលាម៉ោង៦ព្រឹក ៗ ពេលនោះខ្ញុំធ្វើបបរអីឲ្យគាត់ហូប ហៅគាត់មកហូបបបរ ដល់ពេលនោះទៅគាត់ថា អឹហូបមិនចូលទេ ៗ ពេលនេះទៅអឹបែកក្ដួយ១មួយជីវិតហើយ ហើយគេចាប់គាត់ទៅ កូនឡានតូចមកដល់ដាក់កញ្ចៃដែកគ្រឹប១ ៗ

ប៊ុនថន ៖ ចាប់នៅមន្ទីរ?

រាម ៖ ចាប់នៅកន្លែងមន្ទីរអន្តភាព ។

ប៊ុនថន ៖ ប៉ុន្មាននាក់មកចាប់គាត់?

រាម ៖ គ្នាបីនាក់ ។ ស្រណោះគាត់ណាស់ ខ្ញុំរស់នៅជាមួយគាត់ មិនដែលធ្វើឲ្យអ្នកនៅអន្តភាពល្អក់កករទេ បានជាស្រណោះសោកស្តាយគាត់ដែរ ។

ប៊ុនថន ៖ មីងឃើញផ្ទាល់?

រាម ៖ ឃើញផ្ទាល់នឹងភ្នែក បើខ្ញុំអ្នកធ្វើម្ហូបធ្វើអីឲ្យគាត់ លើកបាយអីឲ្យគាត់ ។ ខ្ញុំឈរមើលអីចឹងគ្រាន់តែលាប្រពន្ធកូនពីរបីម៉ាត់ ឡើងឡានទៅ មានតែផ្លូវស្លាប់ ។ ថាទៅ ខ្ញុំរស់នៅជាមួយគាត់មិនដែលមានបញ្ហាអីទេ ហើយអ៊ឹ អៀង សារី ក៏ធ្លាប់រស់នៅជាមួយគាត់ផ្ទាល់ មិនដែលឃើញមានធ្វើបាបអ្នកនៅហ្នឹងចេះចុះ អ៊ឹ ខៀវ សំផន អី ។

ប៊ុនថន ៖ មីងធ្លាប់នៅផ្ទាល់ៗ?

រាម ៖ ធ្លាប់នៅដែរ នៅ៥-១០០នៅដីថៃ ពេលយួនវាយ ។

ប៊ុនថន ៖ ហ៊ូ នឹម ស្រុកកំណើតគាត់នៅណា?

រាម ៖ អត់ស្គាល់ទេ អត់ដឹងថាស្រុកកំណើតនៅណាណី ខ្ញុំអត់ដឹងទាំងអស់ ។

ប៊ុនថន ៖ គាត់នៅមន្ទីរអន្តភាពសិល្បៈ?

រាម ៖ បាទ គាត់គ្រប់គ្រងនៅក្នុងក្រសួងហ្នឹង ។

ប៊ុនថន ៖ គាត់ស្នាក់នៅក្នុងក្រសួង?

រាម ៖ បាទ ។

ប៊ុនថន ៖ ចុះកូនគាត់ប៉ុន្មាននាក់?

រាម ៖ កូនគាត់មានគ្នាបីនាក់ ។

ប៊ុនថន ៖ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

រាម ៖ ប្រុសពីរស្រីមួយ ។

ប៊ុនថន ៖ ធំៗហើយ?

រាម ៖ កូនធំកម្លោះអស់ហើយ មានតែមួយទេនៅតូច ។ គាត់ចាស់ណាស់ហើយ មិនមែនអាយុនៅក្មេងណា គាត់ចាស់អស់ហើយ ។

ប៊ុនថន ៖ ចុះប្រពន្ធគាត់នៅស្រុកអីវិញ?

រាម ៖ ខ្ញុំអត់ស្គាល់ទាំងអស់ ខ្ញុំអត់ដែលហ៊ានសួរគាត់នៅស្រុកណាភូមិណា យើងតូចតាច ។

ប៊ុនថន : គាត់នៅក្នុងតែមន្ទីរទេ?

រាម : គាត់នៅតែក្នុងក្រសួង ។

ប៊ុនថន : ចោះប្រពន្ធកូនគាត់?

រាម : ប្រពន្ធកូនគាត់ក៏នៅជុំគ្នា ។ ថាទៅអន្តភាពសិល្បៈពួកខ្ញុំ តាំងពីគេចាប់គាត់ទៅយ៉ាប់ណាស់ រស់នៅ ។ មានគេមកគ្រប់គ្រង ពិបាករស់នៅណាស់ បន្តិចចាប់នេះ បន្តិចចាប់នោះ បន្តិចចាប់យកអ្នកនេះទៅដាក់គុក ។ ហើពួកខ្ញុំនៅប៉ុន្មាននាក់វេទនាណាស់ ហាត់សិល្បៈគ្រុនក៏ឲ្យគ្នាទៅហាត់ អាអ្នកចូលមកគ្រប់គ្រងថ្មី ។ បើថាគាត់នៅ ដឹងតែយើងឈឺហើយ មិនចេះប្រើមនុស្សឈឺទេ មានតែប្រវេរប្រវារឲ្យចេះរកថ្នាំដាក់ទៅ ឲ្យឆាប់ជា ខ្លាចខាតការងារ ។ បើថាអ្នកមកក្រោយៗ គ្រប់គ្រងក្រោយយ៉ាប់ មួយដើរមិនដឹងគេយកទៅវាយចោលថ្ងៃណា អស់មេហើយ ។

ប៊ុនថន : ក្រោយពីចាប់គាត់ហើយ ចុះប្រពន្ធកូន?

រាម : ប្រពន្ធកូន គេយកទៅទាំងអស់ ។

ប៊ុនថន : ចាប់គាត់ទៅហើយរយៈពេលប៉ុន្មានថ្ងៃបានជាគេមកយកគាត់ទៅទៀត?

រាម : ចាប់គាត់បានរយៈពេលមួយអាទិត្យបានមកយកប្រពន្ធកូនទៅទៀត ។ ហើយអ៊ីគ្រាន់គេចាប់គាត់យកទៅ គ្រាន់តែលាខ្ញុំថា ម៉ាឆាកជីវិតនេះអ៊ីបានជួបមុខតែប៉ុណ្ណឹង ឃើញក្មួយៗបានប៉ុណ្ណឹង ។

ប៊ុនថន : គាត់និយាយជុំគ្នា?

រាម : និយាយជុំគ្នា ។ គាត់និយាយបានជួបជុំក្មួយៗប៉ុណ្ណឹងម៉ាឆាកជីវិត ស្គាល់គ្នាបានតែប៉ុណ្ណឹង ។

ប៊ុនថន : ចុះប្រពន្ធកូនគាត់នៅហ្នឹងទេ?

រាម : ប្រពន្ធក៏នៅហ្នឹង ប្រពន្ធកូនដឹងតែពីយំហើយ បើប្ដីនិយាយអ៊ីចឹង ។ ចុះបើគេគេអូរមកថា គេចាប់ហើយ គាត់មិនដឹង ។

ប៊ុនថន : គេប្រាប់គាត់មុន?

រាម : គេចុចប្រាប់គាត់មុន ។

ប៊ុនថន : គាត់អត់មានរត់ទេ?

រាម : អត់ទេ គាត់មិនរត់តែម្ដង ព្រោះគាត់តាំងចិត្តថា គាត់មិនមានធ្វើអីខុស ។ គាត់តាំងចិត្តថា គាត់មិនរត់តែម្ដង បើគាត់រត់ គាត់ដឹងថាគាត់ខុសហើយបានគាត់គេចខ្លួន ។ ហើយអ្នកអគ្គ

ភាពនៅហ្នឹង មួយៗក៏គេសោកស្តាយគាត់ដែរ ។ មនុស្សត្រង់មិនងាយរត់ទេ ជឿទេ មាន តែអ្នកដែលមិនត្រង់ទេ ងាក់រត់ៗ គេចខ្លួន ។

ប៊ុនថន ៖ ចាប់ហើយប្រពន្ធគាត់នៅក្រសួងផងដែល?

ភាម ៖ នៅហ្នឹងផងដែល ក្រោយមកគេចាប់ទាំងប្រពន្ធ ទាំងកូនទៀត ទាល់តែអស់ទៀត អត់មាន ទុកនៅហ្នឹងទេ ។

ប៊ុនថន ៖ ក្រោយពីចាប់ហើយ គាត់អត់ទៅណាទេ?

ភាម ៖ អត់រត់ដែរប្រពន្ធកូន គាត់ថាបើស្លាប់ៗទាំងអស់គ្នា ។ ហើយមានម្តាយគាត់ចាស់ជរាទៀត យកទៅទាំងអស់ ។

ប៊ុនថន ៖ ម្តាយក្មេកប្តុក៏?

ភាម ៖ ម្តាយបង្កើត ។

ប៊ុនថន ៖ ម្តាយ ហ៊ូ នឹម បង្កើត?

ភាម ៖ ចា៎ ។ កាលនោះ អ៊ី ខៀវ សំផន អ៊ី អៀង សារី ខ្ញុំធ្លាប់នៅ អត់ទេគាត់ដឹងថាស្រួល គាត់មិនដែលធ្វើបាបពីណា ។ អត់ដែលឃើញធ្វើបាបពីណា ។

ប៊ុនថន ៖ ចាប់ហើយអ្នកប្តូរថ្មីមកពីណា?

ភាម ៖ ក្មេចឈ្មោះហើយ ស្រីមកពីខាងនិរតីមក ។ ឲ្យតែពួកនិរតីមក ដឹងតែម្នាក់ៗខ្លាចតែម្តង គេប្រើហិង្សាខ្លាំងណាស់ ។

ប៊ុនថន ៖ គាត់កាច?

ភាម ៖ កាច គេសំឡុតយើង ជូនអីគេចោទដូចថាខ្មាំងអីចឹង ដូចខ្ញុំនៅតែថ្ងៃងាប់ ។

ប៊ុនថន ៖ ម៉េចគេចោទមីង?

ភាម ៖ គេចោទខ្ញុំថា សេអ៊ីអា គេយកខ្ញុំទៅដាក់គុក ។ កាលនោះខ្ញុំអត់ទាន់បាននៅជាមួយអ៊ីទេ ។ អត់ទាន់បាននៅជាមួយអ៊ី អៀង សារី អត់ទាន់បាននៅផ្ទាល់ទេ នៅជាមួយអ៊ី ហ៊ូ យន់ ដឹបូងគេចាប់មីងខ្ញុំ?

ប៊ុនថន ៖ មីង?

ភាម ៖ មីងមួយទៀត គាត់ជាកម្មាភិបាល ។ ដល់ពេលគេចាប់មីងខ្ញុំទៅ បានក្រោយមកទៀតគេ ចាប់ខ្ញុំ ។

ប៊ុនថន ៖ មីងរបស់មីង គាត់ធ្វើអីវិញ?

ភាម ៖ គាត់គ្រប់គ្រងនៅអគ្គភាពសិល្បៈ ។

ប៊ុនថន ៖ មិនមែនមីង វឿន ទេ?

រាម ៖ អត់ទេ នោះនៅតំបន់៣៥នោះទេ គាត់នៅភ្នំពេញ។

ប៊ុនថន ៖ គាត់ឈ្មោះអី?

រាម ៖ ឈ្មោះ ឡុង។

ប៊ុនថន ៖ ស្អីឡុង?

រាម ៖ សោម។

ប៊ុនថន ៖ សោម ឡុង ស្រី?

រាម ៖ ស្រី ប៉ុនគេវាយចោលហើយ។

ប៊ុនថន ៖ គាត់គ្រប់គ្រងហ្នឹងដែរ?

រាម ៖ ចា៎ ហ្នឹងនិរតីចូលមកបានប៉ុន្មានថ្ងៃ គេចាប់គាត់យកទៅ ទាំងប្តីទាំងកូនកំពស់នេះ។ ពេលចាប់គាត់បានមួយអាទិត្យ បានគេមកយកខ្ញុំទៅដែរ។

ប៊ុនថន ៖ ប្តីគាត់ធ្វើអីដែរ?

រាម ៖ ប្តីគាត់ធ្វើនៅហ្នឹងជាមួយគ្នា ស្រុកភូមិជាមួយគ្នា សិល្បៈហ្នឹងដែរ។

ប៊ុនថន ៖ គាត់កូនប៉ុន្មាននាក់?

រាម ៖ កូនស្រីមួយ ទើបនឹងបានកូនមួយ។

ប៊ុនថន ៖ កូនអាយុប៉ុន្មានឆ្នាំ?

រាម ៖ កូនអាយុ៨ឆ្នាំ។

ប៊ុនថន ៖ ស្អី ឡុង កាលនោះ?

រាម ៖ សោម ឡុង។

ប៊ុនថន ៖ ចុះប្តីគាត់ឈ្មោះស្អី?

រាម ៖ ប្តីគាត់ឈ្មោះ លីន។

ប៊ុនថន ៖ ស្អីលីន?

រាម ៖ ត្រកូលដឹងស្អីទេ លីន នោះ។

ប៊ុនថន ៖ ហៅក្រៅ លីន?

រាម ៖ ចា៎។

ប៊ុនថន ៖ ឡុង គាត់អត់មានឈ្មោះហៅក្រៅទៀតទេ?

រាម ៖ អត់ទេ។

ប៊ុនថន : ចុះមានដឹងគាត់ខុសអីបានគេចាប់ទេ?

ភាម : ខ្ញុំអត់ដឹងដូចតែគ្នា គ្រាន់តែប្រជុំថាគាត់នឹងខ្មាំងសេអ៊ីអា ។ ដូចថារូបខ្ញុំអីចឹង ខ្ញុំអត់ដឹងអីហេតុអីបានគេយកខ្ញុំទៅដែរ ហើយខ្ញុំអត់ដឹងអីសោះហ្នឹង ។ ប៉ុនដូចថាទៅដល់នោះប្រធានគុកគេអាណិតអាសូរខ្ញុំចឹងទៅ គេអត់មានធ្វើអី ។

ប៊ុនថន : យកទៅណាវិញ?

ភាម : គេយកទៅដាក់នៅកន្លែងទួលស្លែង យកទៅដាក់អប់រំនៅកន្លែងទួលស្លែង ។

ប៊ុនថន : គេមកចាប់ ឬដឹកមីង?

ភាម : គេឲ្យឡានមកដឹកខ្ញុំយកទៅម្នាក់ឯង ។

ប៊ុនថន : មានដាក់ខ្នោះ?

ភាម : អត់ទេ ដាក់ឡានទៅ ប៉ុនមុននឹងយកទៅដល់កន្លែង គេពន្លាងដានយើងទៅលិចទៅកើត ៗ ។ ទំរាំបានទៅដល់កន្លែងហ្នឹង ហើយថ្ងៃនោះខ្ញុំទៅឈឺផង តែបានអីគាត់គេមកវិញ ហៅខ្ញុំមកវិញហៅមកដាក់សឺរ៉ូម ។

ប៊ុនថន : អឺណា?

ភាម : អឺ យុន យ៉ាត ។ ដាក់សឺរ៉ូមអីហើយចឹងទៅ បានគេមកយកខ្ញុំទៅវិញ ។ ដាក់សឺរ៉ូមអស់ប្រាំប្លោក ។

ប៊ុនថន : កាលយកទៅដំបូងហ្នឹង យោធាមកយក?

ភាម : ពួកយោធាគេមកយក ពួកយោធាតែម្ដង ។

ប៊ុនថន : ឡានអីវិញ?

ភាម : ឡានឈ្នុបតូច ។

ប៊ុនថន : មកដល់មាននិយាយថាម៉េច?

ភាម : អត់ទេ គ្រាន់តែមកដល់គេឲ្យខ្ញុំរៀបចំឥវ៉ាន់ ។

ប៊ុនថន : ប្រាប់ថាទៅណាទេ?

ភាម : អត់មាន ។

ប៊ុនថន : មីងមានសួរគេ?

ភាម : សួរគេ ខ្ញុំយកទៅណា គេអត់ប្រាប់ គេថាទៅដល់គង់ដឹងទេ ទៅៗ ។

ប៊ុនថន : មីងភ័យទេ?

ភាម : អត់ភ័យ ។

ប៊ុនថន ៖ អត់ដឹងថាគេយកទៅទេ?

ភាម ៖ អត់ដឹងថាយកទៅណា ទាល់តែទៅដល់កន្លែងលត់ដំបានដឹង ។

ប៊ុនថន ៖ ម៉េចបានដឹងថានៅទួលស្លែង?

ភាម ៖ ចោះបើកន្លែងទួលស្លែងនោះសម្រាប់អប់រំមនុស្សទូទៅហើយ នរណាដូចថាយើងធ្វើខុស គេយកយើងទៅដាក់កន្លែងអប់រំត្រង់នោះ ។

ប៊ុនថន ៖ ម៉េចបានមិនដឹងថានៅនោះ គេហៅទួលស្លែង?

ភាម ៖ ចោះបើឈ្មោះវាដាក់នៅហ្នឹង នរណាក៏គេហៅទួលស្លែង ។ ទួលស្លែងជិតកន្ទួត ស្គាល់ទេ ។

ប៊ុនថន ៖ កន្ទួតសៀមរាប?

ភាម ៖ ភ្នំពេញយើង ទួលស្លែងនៅជិតភ្នំពេញ កន្ទួតជិតភ្នំពេញ ។

ប៊ុនថន ៖ កន្ទួតផ្លូវបំបែកទៅតាកែវ គេហៅកន្ទួតសៀមរាប?

ភាម ៖ អត់ទេ មិនមែនសៀមរាបនោះទេ ។ កន្ទួតជាយភ្នំពេញយើង ។

ប៊ុនថន ៖ កន្ទួតនៅខេត្តកណ្តាល?

ភាម ៖ ស្គាល់វត្តស្លែងទេ!

ប៊ុនថន ៖ ស្គាល់!

ភាម ៖ ហ្នឹង ។

ប៊ុនថន ៖ យកមកវត្តស្លែង?

ភាម ៖ នោះមិនមែនទួលស្លែងទេ គេហៅវត្តស្លែង ខ្ញុំច្រឡំ ។

ប៊ុនថន ៖ ចឹងមិនមែនទួលស្លែងទេ?

ភាម ៖ មិនមែនទេ ។ នៅវត្តស្លែងជាយភ្នំពេញយើង ។ ខ្ញុំនៅនោះប្រហែលជាប់បីឆ្នាំ ។

ប៊ុនថន ៖ មកដំបូងគេដាក់នៅវត្តស្លែង?

ភាម ៖ កាលគេចាប់!

ប៊ុនថន ៖ ដឹកមក?

ភាម ៖ កាលគេដឹកមក យកមកដាក់នៅវត្តស្លែង ។

ប៊ុនថន ៖ គេមានសួរចម្លើយមិនទេ?

ភាម ៖ គេសួរដែរ យើងនៅហ្នឹងមានធ្វើអីខ្លះ ខ្ញុំថាមិនមានធ្វើអី ។ មានគេអប់រំឲ្យបន្កប់ធ្វើខ្សែខ្លាំង ហើយខ្ញុំថាអត់ អត់ដែលមាននរណាអប់រំខ្ញុំចឹងផង ។ ចុះអត់យើងមិនឆ្លើយថាអត់ អត់មាន

ដល់ហើយគេក៏អត់មានធ្វើអីខ្ញុំដែរ គ្រាន់សួរប៉ុណ្ណឹង ។ ហើយគេក៏ឲ្យខ្ញុំដាំបាយដាំទឹកឲ្យពួកអ្នកដែលគេយកទៅអប់រំទាំងអស់គ្នាហូបទៅ គ្នាប្រហែលជាប់មួយពាន់នាក់ ។

ប៊ុនថន : ជាប់មួយពាន់នាក់?

ភាម : បាទ ខ្លះទៅធ្វើស្រែ ប៉ុនខ្ញុំគេឲ្យនៅចំហុយបាយ មិនបានទៅធ្វើអីទេ ។ ក្រៅពីនោះទៅស្ទូងទៅដក តែឲ្យគេវាយដិច្រំដាក់អត់មានទេ គេគ្រាន់តែអប់យើង ។ នៅហ្នឹងបានប្រហែល ៣ឆ្នាំ ។

ប៊ុនថន : ដល់ឆ្នាំណា?

ភាម : មើល៧៧, ៧៨ គេយកពួកខ្ញុំអីទៅ ។

ប៊ុនថន : នៅដាំបាយ?

ភាម : នៅដាំបាយ ចំហុយឲ្យគេ ។ ពេលដាំបាយហើយ គេចែកគ្នាបន្តិចៗម្នាក់ ។

ប៊ុនថន : មីងមានអ្នកស្គាល់ទេកាលទៅ?

ភាម : មានស្គាល់ ប៉ុនអ្នកនៅនេះអត់មាន ។ ប៉ុនយើងរត់បែកគ្នាអស់ហើយ ស្គាល់គ្នា ។

ប៊ុនថន : អ្នកសិល្បៈដូចមីង?

ភាម : សិល្បៈដែរ ។

ប៊ុនថន : ទៅនោះច្រើនដែរ?

ភាម : ទៅច្រើនតែពួកសិល្បៈទៅនៅនោះ ទៅជិត១០នាក់ ទាំងស្រីទាំងប្រុស ប៉ុនរត់បែកគ្នាអស់ហើយ ។ ដល់ក្រោយនៅនោះប៉ុន្មានឆ្នាំទេ គេចាត់តាំងឲ្យយើងខ្លះធ្វើដូវរទេះភ្លើង ខ្លះទៅខាងបាត់ដំបង បែកដូវគ្នា បែកអស់ហើយ ។

ប៊ុនថន : ចោះបងជីដូនមួយឡុងឃើញនៅទីនោះទេ?

ភាម : អត់ទេ គេវាយចោលហើយ ។

ប៊ុនថន : នៅទីនោះអ្នកណាគ្រប់គ្រង?

ភាម : ឈ្មោះ តាគី ។

ប៊ុនថន : ចុះអ្នកគ្រប់គ្រងជាង១.០០០នាក់នោះ?

ភាម : គាត់ហ្នឹងហើយ ។

ប៊ុនថន : តាអី?

ភាម : តាគី ។

ប៊ុនថន : ឈ្មោះអីគី?

ភាម ៖ នាមត្រកូលអត់ស្គាល់ ។ ដឹងតែគាត់ទទួលខុសត្រូវនៅកន្លែងនោះ ។

ប៊ុនថន ៖ មីងអត់មានឃុំទេ?

ភាម ៖ អត់មានដាក់ចន្សាក់អីទេ តែគ្រាន់គេអប់រំយើង ឲ្យយើងល្អ ។ គេអប់រំយើងតាមសមត្ថភាពរបស់យើង ដូចជាចោទយើងមក មិនមែនអីចឹង គេឲ្យយើងលត់ដំនៅកន្លែងហ្នឹង ។

ប៊ុនថន ៖ ចោះមីងថា ឲ្យមីងដាក់សីរ៉ូម?

ភាម ៖ នោះឯង មកពីនោះមកយកមកដាក់សីរ៉ូម ដាក់សីរ៉ូមហើយគេយកខ្ញុំទៅដាក់កន្លែងនោះដដែលទៀត ។

ប៊ុនថន ៖ ពីណាទូរស័ព្ទទៅ?

ភាម ៖ អ៊ឹ យុន យ៉ាត ។

ប៊ុនថន ៖ គាត់ខលទៅពីណា?

ភាម ៖ ខលទៅពួកទ័ពដែលយកខ្ញុំទៅ ។ ខ្ញុំមិនស្គាល់គេដែរហ្នឹងពួកទាហាន ។

ប៊ុនថន ៖ ម៉េចបានមីងដឹង?

ភាម ៖ ចុះបើខ្ញុំទៅកន្លែងគាត់ ។ គាត់អ្នកដាក់ឲ្យ ហើយគាត់ប្រាប់ចឹង ។

ប៊ុនថន ៖ គាត់ស្គាល់មីង?

ភាម ៖ ស្គាល់ នៅនឹងអន្តភាពសិល្បៈ ព្រោះអីនៅអន្តភាពជាមួយគ្នា ។ គាត់ឃើញខ្ញុំគ្រុនចឹងគាត់អាណិតខ្ញុំ គាត់ប្រាប់គេថាកុំទាន់យកខ្ញុំទៅអី ចាំដាក់សីរ៉ូមឲ្យជាសិនខ្វាចទៅដល់នោះឈឺកាន់តែខ្លាំងគ្មានស្អីទេ ។ ដល់ហើយគាត់អាណិតខ្ញុំ ដាក់សីរ៉ូមឲ្យខ្ញុំជាសិន ។

ប៊ុនថន ៖ កាលនោះអត់ទាន់យកទៅវត្តស្វែងទេ ឬយកទៅរួចហើយ?

ភាម ៖ អត់ទេ បកចុះបកឡើង ។ ដល់ពេលចឹងទៅ ស៊ើបសួរនៅកន្លែងអន្តភាពខ្ញុំទៅថា គេយកទៅហើយ បានគាត់ខ្វាត់ខ្វែងឲ្យទាក់ទងគ្រប់កន្លែងរកឃើញហើយឲ្យដឹកខ្ញុំយកទៅ ។

ប៊ុនថន ៖ កាលនោះ គាត់នៅធ្វើអី យ៉ុត យ៉ាត?

ភាម ៖ យ៉ុត យ៉ាត គាត់ទទួលខាងក្រសួង ដូចថា សាខាខាងក្រសួងសិល្បៈដូចគ្នា ។

ប៊ុនថន ៖ ម៉េចបានជាគាត់ស្គាល់មីង?

ភាម ៖ គាត់ខស្សាហ៍ទៅបង្ហាត់បង្រៀន រៀនសូត្រនៅទីនោះ ។

ប៊ុនថន ៖ បង្រៀនមីង?

ភាម ៖ បង្រៀនទាំងអស់គ្នា ដល់យូរៗទៅគាត់ស្គាល់ លេងសើចទាំងអស់គ្នាក៏ស្គាល់ទៅ ។

ប៊ុនថន ៖ គាត់បង្រៀនពីអី របៀបហាត់ ឬទ្រឹស្តី?

រាម ៖ អត់ទេ គាត់អប់រំខាងទ្រឹស្តី រៀននយោបាយ ។

ប៊ុនថន ៖ កាលនោះគាត់ហៅមីងមកដាក់សឺរ៉ូមនៅពេទ្យ ឬក្រសួង?

រាម ៖ នៅផ្ទះគាត់ ។

ប៊ុនថន ៖ ផ្ទះគាត់នៅម្តុំណា?

រាម ៖ នៅម៉ាជូរស្តាត ។

ប៊ុនថន ៖ គាត់ហៅតែមីងម្នាក់ទេ?

រាម ៖ មានគ្នាច្រើនដែរនៅកន្លែងគាត់ ។ អ្នកនៅជាមួយគាត់ច្រើន មិនតិចណា ។ ចេញពីអគ្គភាពសិល្បៈនេះទៅមានតែខ្ញុំម្នាក់ឯងពេលគេយកខ្ញុំទៅ ។ ប៉ុនសម័យនោះលែងខ្លាចហើយ បើឃើញទូទៅហើយ មិនដឹងគេមិនដឹងយើង ។

ប៊ុនថន ៖ មីងមកដាក់សឺរ៉ូមហើយ បានគាត់និយាយប្រាប់មីង?

រាម ៖ គាត់ថាខំសួរគេនោះ ស្មានមិនថាមិនទាន់ទៅណាមកណាស្មានតែនៅផ្ទះ ដល់ពេលសួរគេទៅដាក់ជិះឡានឃ្មុបមួយ ដល់ហើយគាត់ឲ្យកូនចៅគាត់ស្ទាក់តាមផ្លូវ ។

ប៊ុនថន ៖ ដាក់៥ថ្ងៃ ដល់ហើយមីងអត់ទៅនៅខាងសិល្បៈវិញទេ?

រាម ៖ គាត់អត់ហ៊ានប្រឆាំងគេ ។

ប៊ុនថន ៖ ឡានគេមកយក?

រាម ៖ ឡានគេមកយក អាឡានឃ្មុបដែលយកខ្ញុំទៅ អាឡាននោះមកដដែល ។ ប៉ុន្តែទៅនេះក៏សប្បាយដែរ អត់មានទុកទោសម្នេញអីផង ឃើញគ្នាច្រើនទូទៅ ធ្វើការអីចឹងទៅសប្បាយដែរ គ្មានភ័យកើតទុក ។

ប៊ុនថន ៖ មីងអត់មានដូរទៅការងារផ្សេងទៀតទេ?

រាម ៖ អត់ ខ្ញុំនៅដាំបាយឲ្យគេ ។ បានគេដាក់ចំហុយនៅសឹង ម៉ាកំពូលវាហ្នឹង១០សឹង ។ អើគេកាត់ប្រវែង១នេះបែកគ្នា ទាំរាំមួយឆ្នែត គ្នាច្រើន ។

ប៊ុនថន ៖ សុទ្ធតែបាយចំហុយ?

រាម ៖ សុទ្ធតែបាយចំហុយ ។

ប៊ុនថន ៖ មីងចេញពីនោះទៅនៅខាងណា?

រាម ៖ ខ្ញុំចេញពីនោះមក រត់យួនរបូត ។ ខ្ញុំនៅហ្នឹងទាល់តែយួនវាយ ដល់យួនវាយរត់បែកគ្នារបូតទាល់តែសព្វថ្ងៃនេះ ។

ប៊ុនថន ៖ រត់ទៅណាកាលដំបូង?

ភាម ៖ ចេះតែដើរទៅ មិនដឹងទៅទិសណាទិសណីទេ ខ្ញុំមិនស្គាល់ទេ ។ គេចគ្រាប់ផ្លោង គេចគ្រាប់កាំភ្លើងគ្រាប់អីទៅ ចេះតែដើរទៅគ្នា៤-៥នាក់ រកកោះរកត្រើយមិនឃើញ ។

ប៊ុនថន ៖ មីងរត់ទៅណា?

ភាម ៖ ខ្ញុំរត់មក តាមផ្លូវចេះតែរត់ៗមក ខ្ញុំជួបពួកទ័ព ។ ពេលជួបពួកទ័ពអីចឹងទៅ យួនវាវាយមកខ្ញុំជួបពួកទ័ព ខ្ញុំតាមពួកទ័ពរបូតមក ។ ដល់មកតាមទ័ពមក បានជួបពួកអង្គភាពសិល្បៈខ្ញុំគ្នា៣-៤នាក់ទៀត ចេះតែដើរតាមគេតាមឯង ។ ដល់ក្រោយមកទៀត ជួបពួកទ័ពទៀតមកតាមទ័ពរបូតមក គេរើសនារីស្នាក់ការ ។

ប៊ុនថន ៖ នារីស្នាក់ការ?

ភាម ៖ សម្រាប់សែងអ្នករបួសពីខ្សែត្រៀម ពេលគេឡើងវាយរបួស ។ ដល់ពេលនោះទៅ យើងមានអង្គភាពទៀតទៅ ទៅតាមអង្គភាពទ័ពមជ្ឈិមជាប់មក ។

ប៊ុនថន ៖ គេហៅអង្គភាពអី?

ភាម ៖ អង្គភាពពួកទ័ពមជ្ឈិម ។

ប៊ុនថន ៖ នៅជាមួយពីណា?

ភាម ៖ ជាមួយតា ជៀម ។

ប៊ុនថន ៖ គាត់ប្រធាន?

ភាម ៖ ប្រធាន គាត់គ្រប់គ្រងខាងទ័ព ។ យើងតាមគាត់ហ្នឹងស្រួលដែរហ្នឹង មិនភ័យរត់ទៅណាទៅណីទៀត ។ រត់តែយើងយើងមានអង្គភាពតាមជាប់អីចឹងវាស្រួល ។

ប៊ុនថន ៖ មកនៅខាងណាជាមួយតា ចៀម?

ភាម ៖ រត់តាំងពីពាក់ធ្មឹមរបូតមកបានមកនៅនេះ ។

ប៊ុនថន ៖ ម៉ាខ្សែ?

ភាម ៖ បាទ ជាប់គ្នានៅហ្នឹងរបូត ។

ប៊ុនថន ៖ ឆ្នាំប៉ុន្មានមកដល់នេះ?

ភាម ៖ មកដល់នេះឆ្នាំ១៩៧៩ ។

ប៊ុនថន ៖ វៀតណាមចូលមីងរត់ហែរៗបានមកនេះ?

ភាម ៖ បាន៧៩ហ្នឹងដដែល ។

ប៊ុនថន ៖ មកដល់ដំបូងមីងមកនៅម្តុំភូមិអី?

ភាម ៖ ដូចអត់មានភូមិមានអីទេ រត់របូត ។

ប៊ុនថន ៖ ពេលមកនៅម៉ាឡៃ នៅម្តុំណា?

រាម ៖ កាលមុនមកដល់ម៉ាឡៃ ពួកទ័ពបោះជំរុំម៉ាដួរភ្នំកុយ ភ្នំគ្រាងយើង ហើយនិងគំរៀង អំពិលប្រាំដើម ។

ប៊ុនថន ៖ ចុះនៅហ្នឹងមីងមានដឹងថា គេហៅម៉ាឡៃ ឬមួយមិនទាន់ហៅម៉ាឡៃទេ?

រាម ៖ កាលនោះគេហៅម៉ាឡៃ ។

ប៊ុនថន ៖ កាលមីងមកដល់មានឈ្មោះម៉ាឡៃហើយនៅ ឬមិនទាន់មានទេ?

រាម ៖ ចាំ ។

ប៊ុនថន ៖ គេហៅម៉ាឡៃពេលណា?

រាម ៖ តាំងពីពេលណាទេ ខ្ញុំមិនសូវចាំដែរ ដូច៧៩ចឹងគេហៅម៉ាឡៃ ។

ប៊ុនថន ៖ មីងនៅទីស្នាក់ការពេលរត់មក?

រាម ៖ ចូលអង្គភាពពួកទ័ពមជ្ឈិម ពួកអង្គភាពទ័ពមជ្ឈិម ។

ប៊ុនថន ៖ ធ្វើការអីខ្លះ?

រាម ៖ ខ្ញុំនៅខាងដឹកជញ្ជូនផង នៅខាងស្នាក់ការផង ។ ពេលណាគេអត់វាយចេះ យើងដឹកជញ្ជូនគ្រាប់អីយកឲ្យទ័ព ។ ពេលមានរបួសយើងដាក់ស្នាក់ការសែងអ្នករបួសគគ្នា ពីរគីឡូដីមួយស្នាក់ការៗបានដល់មន្ទីរពេទ្យ ។

ប៊ុនថន ៖ មីងនៅទីនេះរហូតក៏ប្តូរទៅណាទៀត?

រាម ៖ ខ្ញុំនៅ៧៩នៅហ្នឹង នៅហ្នឹងរហូតអត់មានទៅណាមកណាទេ ។ ប៉ុនកាល៧៩ ខ្ញុំនៅនេះបានប៉ុន្មានខែទេ ៨២ខ្ញុំទៅនៅថៃជាមួយអ៊ំ អៀង សារី នៅ៨-១០០ដីថៃ នៅខេត្តច័ន្ទបូរី ។

ប៊ុនថន ៖ ម៉េចបានមីងផ្លាស់ទៅនៅនោះ?

រាម ៖ អ៊ំគាត់យកខ្ញុំទៅ អ៊ំគាត់ស្គាល់ខ្ញុំ គាត់ស្គាល់ខ្ញុំ ។

ប៊ុនថន ៖ គាត់ស្គាល់មីងពេលណា?

រាម ៖ គាត់ស្គាល់យូរហើយ គាត់ស្គាល់ខ្ញុំតាំងពីខ្ញុំនៅសិល្បៈនៅភ្នំពេញ ។

ប៊ុនថន ៖ មីងមានជួបគាត់ ធ្លាប់និយាយលេងជាមួយគាត់?

រាម ៖ គាត់ស្គាល់យូរហើយ ។

ប៊ុនថន ៖ ៨២មីងទៅនៅនោះ?

រាម ៖ ៨២ ទៅនៅ៨-១០០ ។

ប៊ុនថន ៖ ទៅនៅច្រើនទេ?

ភម ៖ មើលពីឆ្នាំ៧៩ខ្ញុំទៅនៅថ-១០០ ៨២ខ្ញុំត្រឡប់មកនេះវិញ ។ ខ្ញុំសុំអ៊ីត្រឡប់មកនេះវិញ ខ្ញុំនឹកអ្នកនៅនេះ ។

ប៊ុនថន ៖ ចឹង៧៩មីងនៅនេះបានមួយរយៈ ហើយទៅនៅថ-១០០?

ភម ៖ ចាំ ។

ប៊ុនថន ៖ មីងទៅនោះធ្វើអីវិញ?

ភម ៖ ទៅនៅហ្នឹង ទៅមើលកុមារ ។ កុមារដូចថា ម្ដាយឪពុកគេទៅទូត ទៅនៅធ្វើទូតខាងកូរ៉េ ខាងនៅចិន នៅញូយ៉កអីចឹងទៅ ។ គេឲ្យខ្ញុំទៅមើលកុមារប្រហែលជាង១០នាក់ ។

ប៊ុនថន ៖ ក្មេងៗ?

ភម ៖ ក្មេងអាយុ១០ឆ្នាំ ៩ឆ្នាំ ៧-៨ឆ្នាំ ១២ឆ្នាំ ។

ប៊ុនថន ៖ កូនរបស់ពីណាខ្លះមីងនៅចាំ?

ភម ៖ អត់ចាំទេ ព្រោះគេចេញទៅអស់ហើយបានខ្ញុំនៅមើល ម៉ែៗគេចេញទៅទូតអស់ហើយ ។

ប៊ុនថន ៖ ចុះអ្នកណានៅគ្រប់គ្រងលើមីង?

ភម ៖ គ្រប់គ្រងនៅលើនោះបង មុិញ ។

ប៊ុនថន ៖ ឈ្មោះអី មុិញ?

ភម ៖ អត់ស្គាល់ទេ បង មុិញ នោះជាកូនរបស់ អៀង សារី ។

ប៊ុនថន ៖ មីងនៅជាមួយគាត់មើលក្មេងៗ?

ភម ៖ ចាំ នៅជាមួយគាត់ ។

ប៊ុនថន ៖ អ៊ឹ អៀង សារី នៅនោះទេ?

ភម ៖ នៅហ្នឹង ។

ប៊ុនថន ៖ នៅជាមួយ?

ភម ៖ គាត់នៅហ្នឹង គ្រាន់ថាគាត់សម្រាកនៅផ្សេង យើងសម្រាកផ្ទះផ្សេង កូនផ្ទះរបស់គាត់មួយតូចសម្រាប់ពីនាក់ប្ដីប្រពន្ធគាត់ ។

ប៊ុនថន ៖ ចោះកូនៗគាត់?

ភម ៖ កូនៗនៅហ្នឹងដែរ ។

ប៊ុនថន ៖ គាត់មានកូនប៉ុន្មាននាក់?

ភម ៖ អ៊ឹកូន៤នាក់ ប្រុសមួយ ស្រីបី ។

ប៊ុនថន ៖ កូនធំ?

រាម ៖ មានចៅអស់ហើយ ។

ប៊ុនថន ៖ ម៉េចបានមីងសំគាត់ត្រឡប់មក?

រាម ៖ ខ្ញុំនឹកអ្នកចាស់ៗ ខ្ញុំនៅតែឯងនៅនេះ ។ ម្យ៉ាងទៀតខ្ញុំឈឺធ្ងន់ផង ខ្ញុំឈឺសន្លប់៨យប់៨ថ្ងៃ គ្មាននរណាថាខ្ញុំរស់ផង ។ ដល់ពេលនេះទៅ តាមអ៊ឹ ដួន ជឿន គាត់ប្រាប់ថាខ្ញុំត្រូវជាសរសៃប្រសាទអីផង រលៀកស្រោមខួរក្បាល ដល់ហើយគាត់ប្រាប់អ៊ឹ អៀង សារី ។ តាមអ៊ឹគាត់មិនឲ្យខ្ញុំមកទេ តែអ៊ឹថាធ្វើម៉េចផ្គាប់ចិត្តខ្ញុំចុះ ចង់ទៅណាបណ្ដោយតាមចិត្តទៅ កុំប្រឆាំង ធ្វើម៉េចឲ្យតែខួរក្បាលខ្ញុំជាវិញ ។

ប៊ុនថន ៖ រាល់ថ្ងៃនេះអត់អីទេ?

រាម ៖ ជាដាច់អស់ហើយ គាត់ព្យាបាលឲ្យខ្ញុំដាច់អស់ហើយ ។

ប៊ុនថន ៖ នរណាព្យាបាល?

រាម ៖ អ៊ឹ ដួន ជឿន ។

ប៊ុនថន ៖ កាលនោះគាត់នៅហ្នឹង?

រាម ៖ នៅហ្នឹងដែរ ។

ប៊ុនថន ៖ គាត់ធ្វើអីវិញ?

រាម ៖ គាត់ធ្វើពេទ្យដុកទ័រ ។

ប៊ុនថន ៖ ចុះឥឡូវគាត់នៅរស់ទេ?

រាម ៖ អត់ទេ តាមស្ដាប់ឮសូរថាគាត់ស្លាប់បាត់ហើយ ។ គាត់ចាស់ហើយ ចាស់ឡើងញ័រៗ គាត់ប៉ុន្មានទេគ្រាន់តែម៉ាស្រុករអីសម្ដេចហ្នឹងឯង គាត់ចាស់ខ្លាំងមែនទែន ។

ប៊ុនថន ៖ គាត់ឲ្យមីងមកនៅម៉ាឡៃវិញ?

រាម ៖ គាត់ឲ្យខ្ញុំមកនៅនេះវិញមក ។ គាត់ថាបើខ្ញុំចង់មក ឲ្យខ្ញុំប្រាប់អ៊ឹទៅបើចង់មកនេះ ឲ្យមកៗ ព្រោះអីខួរក្បាលអត់ពូកែទេឥឡូវនេះ ។

ប៊ុនថន ៖ អ៊ីចឹងគាត់ព្រមឲ្យមក?

រាម ៖ ចា៎ ហើយអ៊ឹក៏គាត់ឲ្យខ្ញុំមកៗ ខ្ញុំសុំប៉ុន្មានដងហើយ ប៉ុនគាត់មិនឲ្យមក ។ តាអ៊ឹ ដួន ជឿន ថាប្រឆាំងអត់បានទេមនុស្សហ្នឹង ថាទៅណាទៅហ្នឹងហើយ អ៊ីចឹងហើយបានមកនៅនេះមក ។ ដល់ខ្ញុំមកនៅនេះបានរយៈប៉ុន្មាន ប្រហែលកន្លះឆ្នាំមិនដឹង គាត់ថាឲ្យខ្ញុំទៅនៅនេះវិញទៅ ។ គាត់ចង់បានខ្ញុំឲ្យនៅជួយមើលក្មេងៗ ព្រោះអីឲ្យគេមើលផ្សេងច្រើនតែធ្វើបាប

ក្មេងៗ គាត់ចង់រកអ្នកណាដែលពូកែមើលក្មេងៗ ព្រោះអីក្មេងៗអស់ហ្នឹង ខ្ញុំមើលខ្ញុំមិនដែលធ្វើបាបវាៗ ទៅរៀនទៅអីក៏ទៅមិនបានដែរ វាតាមពេក យំៗ

ប៊ុនថន : មីងទៅរៀនដែរ?

រាម : រៀនអក្សរដែរ ប៉ុន្តែមិនបានរៀនប៉ុន្មានទេៗ រៀនបន្តិចទៅ ក្មេងវាយំតាមទ្រហឹងពេក អត់មានអ្នកណាមើលជំនួសទេ ម្នាក់ឯងហើយក្មេងចង់១០នាក់ អត់បានទៅណាមកទេៗ

ប៊ុនថន : ចុះឪពុកម្តាយគេខស្សាហ៍មកមើលទេ?

រាម : ពុកម្តាយគេជូនណាគេមកដែរ មកបានត្រឹម២-៣យប់ទៅវិញហើយ ចុះពួកទូតដែលនៅបានយូរៗ

ប៊ុនថន : អត់យកកូនទៅជាមួយទេ?

រាម : អត់យកទៅទេៗ

ប៊ុនថន : ម៉េចបានអត់យកទៅ?

រាម : ដឹងម៉េច ទុកនៅហ្នឹងៗ

ប៊ុនថន : មីងសុំមកនៅម៉ាឡៃបានរយៈពេលប៉ុន្មាន?

រាម : បានប្រហែលកន្លះឆ្នាំគាត់ឲ្យខ្ញុំទៅវិញ ខ្ញុំអត់ទៅៗ

ប៊ុនថន : គាត់អត់ថាអីទេ?

រាម : គាត់អត់ថាដែរ គាត់ដឹងថាខ្ញុំរលាកសរសៃប្រសាទៗ

ប៊ុនថន : មីងនៅហ្នឹងមកខាងអីវិញ?

រាម : មកនៅហ្នឹង មកចូលសិល្បៈវិញដដែលៗ

ប៊ុនថន : ត្រូវចំណង់ចំណូលចិត្តការងារមីងទេ?

រាម : កាលខ្ញុំមកនោះ ឈ្មោះអ៊ឹ ថុនៗ គាត់ចង់បានខ្ញុំនៅជាមួយគាត់ ហើយមួយទៀតអ៊ឹ ជូតចង់បានខ្ញុំឲ្យទៅនៅផ្ទិតរូបថតៗ

ប៊ុនថន : ពីណាវិញ?

រាម : ឈ្មោះ អ៊ឹ ជូត ហើយអ៊ឹ ថុនៗ

ប៊ុនថន : អ៊ឹ ថុន នៅខាងសិល្បៈ?

រាម : អ៊ឹ ថុន គាត់នៅខាងកាសែត គាត់ចង់បានខ្ញុំជួយរៀបការសែត ហើយតា ជូន គាត់ចង់បានខ្ញុំទៅជួយផ្តិតរូបថតៗ ដល់មួយចង់បាន ពីរចង់បានអីចឹងទៅ អ៊ឹ អៀង សារី គាត់

អត្តនោម័តខ្លួនឯងថាមិនបាចទេ ទៅឈ្មោះពូ រិនៗ គាត់ទទួលសិល្បៈនៅនេះក៏គាត់ចង់បានឲ្យនៅអគ្គភាពសិល្បៈវិញទៅ។ មានបានធ្វើអី ទៅមកៗខាងសិល្បៈ។

ប៊ុនថន : សិល្បៈហ្នឹងពូ រិន អ្នកគ្រប់គ្រង?

រាម : ចា៎ ពូរិន អ្នកគ្រប់គ្រង់ គាត់ឲ្យខ្ញុំនៅជួយបង្ហាត់គេ។

ប៊ុនថន : គាត់នៅរស់ទេ?

រាម : គាត់នៅរស់ ឥឡូវគាត់នៅធ្វើការនៅខាងតាកង់។

ប៊ុនថន : ឃុំតាកង់?

រាម : ហ្នឹងគាត់សិល្បៈដែរ។

ប៊ុនថន : ប្រធានសិល្បៈ?

រាម : ចា៎ គាត់នៅភ្នំពេញ ក៏គាត់នៅដែរ នៅអគ្គភាពជាមួយខ្ញុំនៅភ្នំពេញ នៅមជ្ឈិម។ នៅតាកង់ គាត់ធ្វើខាងឃុំ គាត់ខស្សរាហ៍មករៀននៅនេះដែរ ជួបខ្ញុំតែញឹក។

ប៊ុនថន : មីងនៅជាមួយគាត់?

រាម : ចា៎។

ប៊ុនថន : ចោះខាងផ្តិតរូបថត និងកាសែតនៅម៉ាឡៃ?

រាម : នៅនេះដែរ ប៉ុនគាត់ស្លាប់អស់ហើយ។

ប៊ុនថន : កាលនោះកាសែតអីវិញ?

រាម : ផ្តិតរូបថត ដូចថាភ្ញៀវអីមកថតអីចឹង មានគេអ្នកដើរថត។

ប៊ុនថន : មីងថាមានសម្តេចមក ទៅទទួលសម្តេងដែរ?

រាម : ទៅ។

ប៊ុនថន : មកច្រើនដងទេ?

រាម : កាលនោះគាត់មកទស្សនកិច្ចបានពីរដង។

ប៊ុនថន : ចុះកូនរបស់សម្តេចឪ?

រាម : មកដែរ យាងមកដែរ។ ប៉ុន រាបុទ្ធិ គាត់មកនៅហ្នឹងយូរណាស់?

ប៊ុនថន : ពីណា រណឫទ្ធិ?

រាម : ចា៎ គាត់នៅដឹកនជញ្ជូនជាមួយពួកខ្ញុំ គាត់អត់មានយានទៅវិញទេ។

ប៊ុនថន : ចុះព្រះអង្គរាល់ថ្ងៃ?

រាម : ដឹងនៅណាទេ។

ប៊ុនថន ៖ អត់ឃើញនៅហ្នឹងទេ?

រាម ៖ អត់ឃើញទេ ។

ប៊ុនថន ៖ ម៉េចបានមីងដឹងថា គាត់រណឬទ្ធិ?

រាម ៖ ចុះបើអ្នកនៅហ្នឹងគេស្គាល់ ។

ប៊ុនថន ៖ មីងអត់ដែលជួបទេ?

រាម ៖ ឥឡូវអត់ដែលជួបទេ ។

ប៊ុនថន ៖ កាលពីមុន?

រាម ៖ មុនៗក៏អត់ដែរ គ្រាន់ថាគាត់នៅនេះ នៅបានប៉ុន្មានដែរនៅខាងដីកជញ្ជូន ។ គេមិនឲ្យគាត់ទៅ តែគាត់ចង់ទៅ ។

ប៊ុនថន ៖ មីងនៅនេះមានវាយគ្នាជាមួយកម្លាំងខាងក្នុងទេ?

រាម ៖ វាយ តាមនេះមានវាយគ្នាខ្លាំងណាស់ ។ វាយដូនអីដីកជញ្ជូនរត់ស្មើរតែមិនរួចដែរហ្នឹង ។ វាយខ្លាំងណាស់ ដូនណាទៅយកអង្ករយកគ្រាប់អីនៅដីថៃព្រលឹម យួនវាយព្រលឹមៗ រត់ប្រសាចជើង ។

ប៊ុនថន ៖ ចុះមីងរៀបការឆ្នាំណា?

រាម ៖ កាលខ្ញុំការ៨០ប៉ុន្មានទេ មិនចាំទេ ។ ការនៅនេះ ប៉ុននៅខ្លាំងរាប់ ។

ប៊ុនថន ៖ កាលនោះមីងនៅក្រុមសិល្បៈ?

រាម ៖ អត់ទេខ្ញុំចេញពីក្រុមសិល្បៈ ទៅនៅខាងដីកជញ្ជូនម្តង ។

ប៊ុនថន ៖ នៅសិល្បៈបានប៉ុន្មានឆ្នាំ?

រាម ៖ នៅសិល្បៈបានពីរ-បីឆ្នាំ ដល់ពីនេះទៅ ខ្ញុំសុំគេទៅនៅខាងដីកជញ្ជូនម្តង នៅតែខាងសិល្បៈពេក ។

ប៊ុនថន ៖ នៅដីកជញ្ជូនបានស្គាល់គ្រួសារអ្នកមីង?

រាម ៖ ចាំ ។

ប៊ុនថន ៖ កាលនោះរៀបការឬចាប់គូរៗ?

រាម ៖ អត់ទេ រៀបការ គេពាក់ក្អួងពាក់អីម៉ាជំនាន់នោះ ។

ប៊ុនថន ៖ កាលនោះឆ្នាំប៉ុន្មាន?

រាម ៖ កាលនោះមិនដឹងជា៨០ប៉ុន្មានទេ មិនចាំ ។

ប៊ុនថន ៖ ការហើយ មីងនៅនោះរហូត ឬផ្លាស់ប្តូរទៅណាទៀត?

រាម :	ខ្ញុំការបានប៉ុន្មានខែ យួនវាយ យើងរត់ទៀត ។ រត់ចេញពីកន្លែងនេះ ដល់ហើយរដ្ឋាភិបាលយើងទិញដីគេមួយកន្លែងទៀតនៅ៨-៨៥ ដើម្បីជម្លៀសប្រជាជនយើងនៅព្រំដែនយកទៅដីថ្មី ។

ប៊ុនថន :	មីងទៅនៅនោះ?

រាម :	ទៅនៅនោះទាំងអស់គ្នា ម៉្តុំត្រង់ហ្នឹង ទាំងអស់គ្នាតែម្តង ។ គេយកតែប្តីៗយកទៅមុខ ប្រពន្ធៗនៅដីថៃកុំឲ្យពិបាករត់លួន គ្នាអ្នកមានកូនមានចៅយ៉ាប់ណាស់ ។

ប៊ុនថន :	មីងនៅទីនោះដល់ប៉ុន្មានបានមីងមកនៅនេះ?

រាម :	នៅទីនោះដល់ វាយបែកខ្ទាំងរាប់ វាយបែកអីនេះអស់បានយកប្រពន្ធទ័ពប្រពន្ធអីមកនៅនេះវិញ ។

ប៊ុនថន :	មីងនៅផ្ទះរាល់ថ្ងៃ?

រាម :	នៅហ្នឹងឯង ។

ប៊ុនថន :	គេចាប់ដីនៅឬចែក?

រាម :	អត់ទេស្រេចខ្លួនយើង នរណាគេមកមុនអីចឹងទៅ ។ ចុះមានឡានតែពីរបី យើងដឹកតាមគ្រួសារៗមក ។ នរណាគេមកមុនអីចឹងទៅ គេចាប់បានដីធំ ។

ប៊ុនថន :	មីងមកក្រោយ?

រាម :	ខ្ញុំមកក្រោយគេ បានដីតូច ។

ប៊ុនថន :	ចោះផ្លូវចេញ តាមផ្លូវណា?

រាម :	ផ្លូវចេញទៅក្រោយនេះក៏មាន ប៉ុន្តែផុកណាស់ ខែវស្សាយ៉ាប់ណាស់ ។

ប៊ុនថន :	ចុះពូនៅទេរាល់ថ្ងៃ?

រាម :	អត់ទេ គាត់ស្លាប់យូរហើយ ។

ប៊ុនថន :	ស្លាប់ដោយសារអី?

រាម :	គាត់ទៅអារឈើ ហើយចោរប្លន់យកម៉ាស៊ីន ដល់ហើយបាញ់គាត់នៅព្រៃ ។

ប៊ុនថន :	ស្លាប់ឆ្នាំប៉ុន្មាន?

រាម :	ឪអាចាន់ស្លាប់ខ្ទង់២០ឆ្នាំហើយ តាំងពីយើងមិនទាន់ផ្តាច់ខ្លួន ។

ប៊ុនថន :	ឆ្នាំ៩០ជាង?

រាម :	ហ្នឹងហើយ ។

ប៊ុនថន :	ចុះកូនប៉ុន្មាននាក់?

ភាម ៖ កូនពីរប្រុសទាំងពីរ ហើយពិការមួយទៀត ។

ប៊ុនថន ៖ ពិការតាំងពីតូច?

ភាម ៖ អត់ទេ កូនខ្ញុំចេះដើរហើយ ។ ម៉ាជិនាន់យើងរត់នោះ អត់មានថ្នាំចាក់ការពារជំងឺខ្វិន ហើយគ្រុនក្តៅតែមួយថ្ងៃសោះ កូនដើរអត់រួច ។

ប៊ុនថន ៖ ខ្វិនរហូតដល់ពល់ថ្ងៃ?

ភាម ៖ ខ្វិនដល់ពល់ថ្ងៃ ជិះតែរទេះ វេទនាណាស់ចិញ្ចឹមកូន ។

ប៊ុនថន ៖ ចុះមីងធ្វើអ្វីក្រោយប្តីស្លាប់ហើយ?

ភាម ៖ ក្រោយប្តីស្លាប់ហើយខ្ញុំស៊ីឈ្នួលគេ អត់មានស្រែមានចំការណា ។

ប៊ុនថន ៖ ពល់ថ្ងៃមានចំការទេ?

ភាម ៖ អត់មានទេ ។

ប៊ុនថន ៖ មានរបប?

ភាម ៖ អត់ របបអីក៏អត់មាននឹងគេ ។

ប៊ុនថន ៖ របបពេលមកដល់ដំបូង មានចែករបប?

ភាម ៖ មកដល់ដំបូងនៅក្នុងទ័ពហ្នឹងយើងបានរបបដែរ ក្រោយមកទៀតមក គេផ្តាច់របបយើងអស់ទៅ ។

ប៊ុនថន ៖ ពេលណាគេផ្តាច់របប?

ភាម ៖ គេបើកឲ្យខ្ញុំបានប៉ុន្មានដងទេ បើកបានប៉ុន្មាន២-៣ដងហ្នឹង ហើយគេផ្តាច់របបរបូតទៅ ។ មិនដែលបើកអីគេបានទេ ។

ប៊ុនថន ៖ កាលមិនទាន់ផ្តាច់ខ្លួននៅធ្វើចំការ?

ភាម ៖ កាលមិនទាន់ផ្តាច់ខ្លួនក៏មិនបានធ្វើចំការធ្វើអីដែរ ។

ប៊ុនថន ៖ ធ្វើអីវិញ?

ភាម ៖ ដើរស៊ីតែឈ្នួលគេ ។

ប៊ុនថន ៖ សព្វថ្ងៃធ្វើអីវិញ?

ភាម ៖ លក់ដូរបន្តិចបន្តួចចិញ្ចឹមកូនតក់ៗ ទៅលែងរួចហើយ បើងាកឈឺៗ ។

ប៊ុនថន ៖ ខ្ញុំចង់សួរមីងមួយសំណួរ មុនពេលផ្តាច់ខ្លួនហើយក្រោយពេលផ្តាច់ខ្លួន ជីវភាពរស់ របរខុសពីមុន ឬមួយនៅដដែល?

រាម ៖ ដូចជាមិនមានផ្លាស់ប្តូរអីទេដដែល ពីយើងផ្តាច់ខ្លួន ។ មុនពេលផ្តាច់ខ្លួនក៏យើងនៅចាយលុយដដែល ដល់ផ្តាច់ខ្លួនមកក៏យើងនៅតែចាយលុយ ព្រោះយើងចាយលុយយូរហើយ ។

ប៊ុនថន ៖ ដូចជីវភាពអត់សូវប្លែកទេ?

រាម ៖ ប្លែកដែរ ដូចពីមុនយើងអត់ ដល់យើងឥឡូវប្លែកយើងរកបានដូចបងប្អូន យើងប្លែកច្រើន ពីដើមយើងអត់មានផ្ទះអត់អីចឹង ។

ប៊ុនថន ៖ ចង់សួរមីងមួយទៀត នៅក្នុងសម័យបីឆ្នាំមីងដែលធ្លាប់ជួយគេទេ ដូចជាឲ្យរបបអាហារ សម្លៀកបំពាក់ដល់អ្នកដទៃ ធ្លាប់ជួយអ្នកផ្សេង?

រាម ៖ រឿងសម្លៀកបំពាក់ របស់របរធម្មតាអត់មានអីខ្វះខាតប៉ុន្មានទេ យើងស្លៀកពាក់ធម្មតា ។

ប៊ុនថន ៖ ដូចជួយអ្នកដទៃ?

រាម ៖ ធ្លាប់ដែរ ដូចថាអ្នកណាដែលអត់ខ្វាំងអីចឹងទៅ យើងមានខ្លួនឯងចែកគ្នាស្លៀកពាក់ទៅ ។

ប៊ុនថន ៖ មីងធ្លាប់នៅជាមួយលោកតា ខៀវ សំផន?

រាម ៖ អឺគាត់នៅខាងទ័ពដែរ ពេលណាគាត់មកលេង មានការអីនៅផ្ទះអ៊ី អៀង សារី នៅកន្លែង ៨-១០០ ។ គាត់មកលេង ទស្សនកិច្ច នៅដេកលេងអីនៅហ្នឹងទៅ ប៉ុន្តែមិនដែលឃើញគាត់មានស្អីៗមិនដែលមាន ។ គាត់និយាយលេងសើចជាយើងធម្មតា មិនដែលឃើញមានបាតុភាពអីយើងល្អក់កករទេ ។

ប៊ុនថន ៖ មួយទៀតទាក់ទងជាមួយបងប្អូនជីដូនមួយមីងឈ្មោះ ឡុង ក្រោយមកមីងមានដែលឮ ដំណឹងគាត់ចាប់ទៅណា ដោយសារអីបានគេចាប់?

រាម ៖ ខ្ញុំអត់ដឹងដែរ ប៉ុន្តែដឹងតែគេចាប់គាត់យកទៅ ។

ប៊ុនថន ៖ កាលនោះគាត់នៅខាងមន្ទីរអី?

រាម ៖ នៅអគ្គភាពសិល្បៈ ។

ប៊ុនថន ៖ គាត់នៅជាមួយមីងទេ?

រាម ៖ ចា៎ នៅជាមួយគ្នា ផ្ទះជាប់គ្នា តែមិនដឹងចាប់យកទៅណា ។ តាមដែលគាត់មកជួបខ្ញុំ គេឲ្យគាត់មកជួបខ្ញុំមួយភ្លែតដែរ គ្រាន់តែគាត់មកជួបខ្ញុំថាប៉ុណ្ណឹងមីងលាក្មួយឯងអស់មួយជីវិតហើយ ។

ប៊ុនថន ៖ មីងនោះអាយុប៉ុន្មាន?

រាម ៖ មីងនោះអាយុ៤០ គាត់គ្រាន់តែប្រាប់ខ្ញុំប៉ុណ្ណឹង ។ ហីកូននោះវាអត់ចង់ទៅតាមម៉ែវាទេ វាយំអត់ចង់ទៅតាមម៉ែ វាថាមិនទៅទេ យកវាទៅវាយចោល ។

ប៊ុនថន ៖ ម៉េចបានកូនហ្នឹងដឹង?

រាម ៖ មិនដឹងម៉េច បើវាឆ្លើយអីចឹង ។ ម៉ែវាគេឲ្យមកជួបខ្ញុំ ជួបយប់ទៀត ជួបហែលជាមួយម៉ោងហ្នឹងគេឲ្យជួប ដល់ហើយបែកគ្នារបូត រហូតដល់សព្វថ្ងៃ ។ ដល់ពេលទៅផ្ទះ សួរអ្នកផ្ទះក៏អត់ឃើញទេ ។

ប៊ុនថន ៖ ពីមុនគាត់ធ្លាប់នៅជាមួយ ធុច ទេ?

រាម ៖ នៅអង្គភាពហ្នឹងដែរ គាត់គ្រប់គ្រងហ្នឹងដែរ ប៉ុន្តែខ្ញុំមិនដែលឃើញមានស្អីដែរ ។

ប៊ុនថន ៖ ខ្ញុំចង់សួរពីម៉ាឡៃវិញ ពេលណាមានវត្តនៅម៉ាឡៃ?

រាម ៖ វត្តមាន ។

ប៊ុនថន ៖ មីងមកដល់ឆ្នាំ១៩៧៩?

រាម ៖ វត្តនៅខាងនេះ ក្រោយមន្ទីរពេទ្យ វត្តចាស់ ។

ប៊ុនថន ៖ គេហៅវត្តអី?

រាម ៖ គេហៅវត្តចាស់ ។

ប៊ុនថន ៖ កាលនោះមានលោកទេ?

រាម ៖ មាន ។

ប៊ុនថន ៖ ៧៩មាន?

រាម ៖ យើងទើបមកនៅ យើងចាប់ផ្តើមបង្ករបង្កើត មានវត្តមានអី ។ មានវត្ត មានលោកទៅ ។ កាលយើងមកនៅអត់ទាន់មានទេ ដល់ពេលយើងមកនៅយូរទៅយើងបង្កើត ។

ប៊ុនថន ៖ ប្រហែលឆ្នាំប៉ុន្មាន?

រាម ៖ មានតាំងពីឆ្នាំ១៩៧០ ៨២ហ្នឹងហើយ ព្រោះអីកាលខ្ញុំទៅថៃ-១០០ វា៧៩អត់ទាន់មាន ពេលខ្ញុំមកវិញ ឃើញវត្តគេកើតហើយ ។ ខ្ញុំមក៨២ហ្នឹង ឃើញវត្តគេកើតហើយ ។

ប៊ុនថន ៖ ប៉ុន្តែមានលោកទេ?

រាម ៖ មានច្រើនដែរ លោកប្រហែលខ្ទង់១០អង្គដាង ។

ប៊ុនថន ៖ មានធ្វើបុណ្យភ្ជុំ បុណ្យអីដែរ?

រាម ៖ មាន ដល់ខែភ្ជុំគេវេចនំទៅវត្ត ។

ប៊ុនថន ៖ កង់ទីព?

រាម ៖ ទ័ពយើងហ្នឹងហើយអ្នកធ្វើ ធ្វើបុណ្យទានអីចឹងទៅ មានយាយជី មានតាអាចារ្យអីចឹងដូចរាល់ថ្ងៃ មានវត្តមានវាធ្វើ ។

ប៊ុនថន ៖ ខ្ញុំអស់អីសួរមីងហើយ មីងមានអីបន្ថែមទាក់ទងរូបហ្នឹងទេ ពត៌មានអីបន្ថែម?

រាម ៖ អត់ទេ មានអីបន្ថែម ។

ប៊ុនថន ៖ អ៊ីចឹងចាំខ្ញុំសួរមីងក្រោយ ។ អរគុណមីង ។

-ចប់-